# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះទេពសត្ថា ស្វរ-ហយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

---


| ផ្នែកអក្សរសាស្ត្រ | បញ្ជីរឿង | ទំព័រ |
|---|---|---|
| អ្នកឧកញ៉ាឈឹម-ក្រសេម | ព្រះរាជពង្សាវតារភាគទី១ សម័យនគរភ្នំ (តចប់) | ៤០១ |
| នាងនេត្រ-ឡាំងសី | របាំថ្នាំជក់ (តមក-ចប់) | ៤១៧ |
| លោក ភ័យ-ប៊ុក ក្រមការ | សុភាសិតភាគទី១ (តមក-ចប់) | ៤២៧ |
| — | ប្រជុំពាក្យព្រេងនិងជារបនាបារាំង (តមក-ចប់) | ៤៣២ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម | ប្រវត្តិសាស្ត្រសង្ខេប ប្រទេសឥណ្ឌា (តមក).. | ៤៤១ |
| អ្នកឧកញ៉ា ព្រះឃ្លាំងឧង | រឿង «ភោគកុលកុមារ» (ពាក្យកាព្យ) (តមក) | ៤៥០ |
| **ផ្នែកសាសនា** | | |
| មហាឧម-ណាគ្រី | មុនីសុភាសិត | ៤៥៦ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម | ពន្លឺអាស៊ីទ្វីប (តមក) | ៤៦៤ |
| **កំណត់និងប្រវត្តិការណ៍** | | |
| ភិក្ខុ សួន-ស៊ុន | បុណ្យបូជាសពអ្នកអាចារ្យហ៊ុន-សុជ (តចប់)... | ៤៧០ |
| ក្រសួងធម្មការ | អំពីការតាំងចៅអធិការថ្មី (តមក) | ៤៧៨ |


---

ឆ្នាំទី ២១ — លេខ ៦ ខែមិថុនា ឆ្នាំ ១៩៤៩ — ដំឡៃជាវ ១ ឆ្នាំ ៩៦ រៀល ។

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Luong Nibandhamantrî NHOK-THÈM, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déb Sattha So-HAY membre de la Commission du Tripitaka

## TABLE DES MATIÈRES

**Partie littéraire :**

| | | page |
|---|---|---|
| Neak Oknha Chim-Krasem député | Histoire ancienne du Cambodge, 1er partie (suite et fin) | 401 |
| Néang NET-LANGSEY | Culture du tabac au Cambodge (suite et fin) | 417 |
| M. Ray-Buc kramakar (I. B.) | Proverbes et maximes tome I (suite et fin) | 427 |
| —id— | Recueil des Dictons et des devises français (suite) | 432 |
| Luong Nibandhamantrî NHOK-THÈM | Histoire sommaire de l'Inde (suite) | 440 |
| Vén. Neak Oknha Breah Khleang NONG | « Bhog kulkumar » (en vers) (suite) | 450 |

**Partie religieuse:**

| | | |
|---|---|---|
| Maha OM-NAGRY | Munisubhāsit | 456 |
| Luong Nibandhamantrî NHOK-TEÈM | Lumière de l'Asie (suite) | 464 |

**Notes et chroniques**

| | | |
|---|---|---|
| Vén. SUON-SURIN | Compte-rendu sur les cérémonies de crémation de l'Achar HIN-SUCH (suite et fin) | 470 |
| Ministère des cultes | Nomination des nouveaux chau Adhikar (suite) | 478 |

21e Année: No 6 Juin 1949 — Prix d'abonnement: 96$00 par an.

# ព្រះរាជពង្សាវតារភាគទី ១

# សម័យនគរភ្នំ

ក្រសេម ទេពពិទូរ រៀបរៀង

(តចប់)

---

ព្រះបាទកោណ្ឌញ្ញ ព្រះនាងសោមាទេវី
ព្រះពាលាទិត្យ សរស្វតី ភរិយាវិស្វរូប
រាជឱរសច្បង មហេន្ទ្រទេវី មហេសីមហេន្ទ្រវរ្ម័ន
នៅអនិន្ទិតបុរៈ រាជេន្ទ្រវរ្ម័ន ។

ព្រះបាទកោណ្ឌញ្ញជយវរ្ម័ន ប្រាកដព្រះកិត្តិយសជាមហាធិរាជ, ជាមហាក្សត្រិយ៍សឹក, ជារាជាធិរាជ ឬចក្រពត្តិ ក្នុងប្រវត្តិសាស្ត្រ ។

## ព្រះបាទរុទ្រវរ្ម័ន

**ព. ស. ១០៥៤ - ១០៨៨, គ. ស. ៥១១ - ៥៤៤**

ព្រះរុទ្រវរ្ម័នអង្គនេះ ប្រហែលជារាជឱរសព្រះបាទកោណ្ឌញ្ញ-ជយវរ្ម័ន ដែលមានព្រះនាមដើមថា ពាលាទិត្យ, វេលាឡើងសោយរាជ្យ គេថ្វាយព្រះបរមនាមថា រុទ្រវរ្ម័ន, ទ្រង់មានព្រះអគ្គមហេសីព្រះនាមរុទ្រទេវី ។ ព្រះបាទរុទ្រវរ្ម័នទ្រង់មានព្រះរាជឱរស ១ អង្គ តែមិនប្រាកដព្រះនាមដូចម្តេច ហើយព្រះរាជឱរសនោះប្រហែលជាប្រសូតអំពីព្រះជាយាដទៃ ក្នុងពេលមុនបានសោយរាជ្យ មិនមែនជា

ប្រសូតអំពីព្រះនាងរុទ្រទេវីដ៏ជាអគ្គមហេសី ។ កាលទឹងទ្រង់សោយរាជ្យ ត្រូវព្រះរាជឱរសដែលមិនស្គាល់ព្រះនាមនោះ ក្បត់ដណ្ដើមរាជបល្ល័ង្ក ទ្រង់គោងសម្លាប់ព្រះឱរសក្បត់នោះបង់ហើយ ទើបបានឡើងគ្រងបល្ល័ង្ករាជ្យតមក ។

ការផែនដី: ក្នុងពេលដែលប្រទេសខ្មែរផ្លាស់ផែនដីថ្មី តាំងមានក្បត់ផែនដីផងនេះ ជាឱកាសឲ្យចាម្បក់ការបះបោរឡើង ដើម្បីដោះខ្លួនឲ្យរួចអំពីអំណាចខ្មែរ កាលព្រះបាទរុទ្រវរ្ម័នទ្រង់ជ្រាបហើយ ក៏ស្ដេចលើកកងទ័ពទៅកម្រាប បានត្រឡប់រាបទាបដូចដើមវិញ ។

## សាងព្រះនគរបុរី

ក្រោយកម្រាបចាមហើយ បានស្ដេចទៅសាងព្រះរាជធានីថ្មី នៅស្រុកព្រៃកប្បាស សិងមិនឆ្ងាយប៉ុន្មានពីនគរភ្នំប្រាកដ ឈ្មោះនៅក្នុងពាក្យសច្ចាប្រណិធាន (ផឹកទឹកសំបថ) ថា "នគរអធិបតី" (១) តែក្រោយមកគេហៅថា នគរបុរី នៅមានភស្ដុតាងប្រាកដ ដរាបដល់សព្វថ្ងៃនេះ ។ ក្រៅពីនេះទ្រង់បានសាងទេវស្ថាន ១ នៅភ្នំដា ជិតនគរបុរី ទឹងឲ្យចា-រឹកសិលាចារឹក ១ ទុកនៅប្រាសាទតាព្រហ្ម (បាទី) ។

---

១ ឈ្មោះនេះបានក្លាយទៅជារឿងព្រេងគេហៅថា "នគរស្លាប់ក្ដី" រឿងព្រេងនេះអ្នកស្រុកព្រៃកប្បាសនៅចាំ និងនិយាយដំណាលបានហូរហែ ដរាបដល់សព្វថ្ងៃនេះ ។

មិនដឹងជាដោយហេតុអ្វី ដល់មកក្នុងឆ្នាំ ព. ស. ១០៨៨ ព្រះបាទធុរ័នស្រាប់តែគៀសព្រះអង្គបាត់អំពីព្រះនគរទៅ (១) ។ ព្រះស្រីសុរ័នបានទទួលគ្រងរាជសម្បត្តិតមក ។

## ព្រះចាន់ស្រីសុរ័ន

**ព. ស. ១០៨៨-១១០៩, គ. ស. ៤៦៨-៤៨៩**

ព្រះស្រីសុរ័នអង្គនេះ ជាព្រះរាជឱរសព្រះបាទធុរ័នឬជាព្រះរាជវង្សដទៃទេ គេមិនអាចដឹងបានជាប្រាកដ ស្ដេចមកពីនគរណាក្នុងរវាងវេលានោះក៏បានទទួលគ្រងរាជសម្បត្តិតអំពីព្រះបាទធុរ័ន, មានព្រះបរមនាមសម្រាប់ហៅ ២ យ៉ាងទៀត គឺស្រីសុរ័ន និងធុរ័ន, ទ្រង់មានព្រះអគ្គមហេសី ទីង ព្រះរាជឱរស ព្រះរាជធីតាឬទេ មិនប្រទះដំណឹង ។

ការផែនដី: ក្រោយដែលបានទទួលពិធីរាជាភិសេកហើយ ព្រះបាទស្រីសុរ័ន ទ្រង់តែងរាជទូតឲ្យនាំរាជសារទូររាជបណ្ណាការ ទៅសុំចងសម្ពន្ធមេត្រីភាពនឹងស្ដេចចិន, ខាងស្ដេចចិនក៏បានទទួលចងមិត្រភាពផង ហើយតែងរាជទូតឲ្យនាំព្រះរាជសារទូររាជបណ្ណាការ មកតបវិញតាមទំនៀម ។ ព្រះមហាក្សត្រិយ៍ខ្មែរបានទ្រង់តែងរាជទូតឲ្យទៅសុំចងជាសម្ពន្ធមិត្រនឹងស្ដេចក្រុងចិនរាប់ជាគ្រាទី ៤ ក្នុងរជ្ជកាលនេះ ។

---

១ តាមផ្លូវសម្ពង្សខ្មែរថា ប្រហែលជាមានព្រះរាជវង្សអង្គនិមួយគិតក្បត់ កាលទ្រង់ជ្រាបហើយទ្រង់មិនត្រូវការនឹងគស្ទូ ទើបទ្រង់គេសទៅដោយស្ងាត់ ។

ក្រោយដែលបានចងសម្ពន្ធមេត្រីភាពជាមួយនឹងស្តេចចិនហើយ មានសេចក្តីប្រាកដក្នុងពង្សាវតារចិនថា ស្តេចនគរលិនយី (ចាម្ប៉ា), ចង់វាយស្រុកកោះដីរបស់ចិនយកមកជាសម្បត្តិរបស់ខ្លួន ទើបបានបញ្ជូនរាជទូតឲ្យសូមកងទាហានស្តេចនគរភ្នំ (ខ្មែរ) ទៅជួយវាយ តែស្តេចនគរភ្នំ គឺព្រះបាទឥន្ទ្រវរ្ម័ន ពុំព្រមព្រះរាជទានតាមសុំ ព្រោះទ្រង់បានចងសម្ពន្ធមេត្រីភាពជាមួយនឹងស្តេចចិនទៅហើយ ។ ន័យ ១ ទៀត ចាម្ប៉ាឯងក្នុងវេលានោះនៅក្នុងអំណាចឥទ្ធិពលរបស់ខ្មែរ មិនត្រូវពីក្រឹកអាណាខេត្តដោយអំពើចិត្តឯងដូច្នេះ ទើបមិនទ្រង់ប្រោសព្រះរាជទានទាហានតាមសុំ ។

## សាងព្រះនគរស្រេស្ឋបុរៈ

ព្រះបាទស្រេស្ឋវរ្ម័ន បានស្តេចឡើងទៅសាងព្រះរាជធានីថ្មីនៅបា-ដោម ក្នុងខេត្តស្ទឹងត្រែង ចម្ងាយ ១២ គីឡូម៉ែត្រពីស្ទឹងត្រែង ហៅថា "ស្រេស្ឋបុរៈ" ហើយស្តេចទៅគង់នៅក្រុងថ្មីនេះ បោះបង់ចោលនគរភ្នំស្រឡះ នគរភ្នំបានរលាយទៅក្នុងឆ្នាំ ព. ស. ១០៩៣ (គ. ស. ៥៥០) ។

កាលដែលព្រះបាទស្រេស្ឋវរ្ម័នទៅតាំងព្រះរាជធានីនៅដែនដីភាគខាងលើនោះ បានប៉ះសុគានឹងព្រះភវវរ្ម័នជាឧបរាជធំ សឹងតាំងរាជធានីនៅត្រង់មជ្ឈមនៃទន្លេមេគង្គ ដាច់ខ្ទោះ ១ន ទឹង ចាដែក បានកើតជាសង្គ្រាមគ្នាឡើងក្នុងប្រទេស ដោយព្រះភវវរ្ម័នជាអ្នកលើកកំឡាំង

មកវាយក្រុងស្រីស្រុបុរៈមុន ។ ផលនៃការសង្គ្រាមក្នុងទីបំផុត ព្រះភវវរ្ម័ន មានជ័យជំនះ បានគ្រប់គ្រងផែនដីទាំងមូល ដោយដាច់ខាត ។

ក្នុងគ្រាសង្គ្រាមនោះ ព្រះភវវរ្ម័ន ជារាជបុត្រក្សត្រិយ៍ចាម្ប៉ាបានឱកាស ដោយឃើញខ្មែរជាប់ដៃច្បាំងគ្នាឯងក្នុងប្រទេស ក៏ប្រកាសខ្លួនជាឯករាជ្យភ្លាម ៗ ពិតដូច្នេះ ខាងខ្មែរកំពុងជាប់ដៃច្បាំងគ្នា ក៏តោងបណ្ដោយឲ្យចាម្ប៉ាតាំងខ្លួនទៅតាមការ, កាលឈប់ច្បាំងហើយ ព្រះភវវរ្ម័ន ក៏មិនទ្រង់លើកកំឡាំងទៅបង្ក្រាបចាម្ប៉ា ដោយទ្រង់យល់ឃើញថា ទាហានរបស់ព្រះអង្គស្គតស្លាប់ជាច្រើន ដែលរស់នៅកំពុងនឿយហត់ខ្លាំងណាស់ ។ គិតបរិមាណឆ្នាំដែលចាម្ប៉ាធ្លាក់មកនៅក្រោមអំណាចខ្មែរ តាំងពីក្នុងរជ្ជ-កាលព្រះបាទកោណ្ឌញ្ញជយវរ្ម័ន មកដល់ក្នុងរជ្ជកាលព្រះបាទស្រីស្រុវរ្ម័ន (ព. ស. ១០២៦ - ១០៩៣) រួមប្រមាណ ៦៨ ឆ្នាំ ។

## ព្រះបាទភវវរ្ម័នទី ១

ព. ស. ១១០៨ - ១១២៨, គ. ស. ៥៦៥ - ៥៨៥

មានព្រះរាជវង្ស ១ អង្គ ព្រះនាម "វីរវរ្ម័ន" ជាព្រះរាជវង្សនៅនគរភ្នំ ត្រូវតាំងឧបរាជឲ្យទៅគ្រប់គ្រងផែនដីភាគខាងលើ តាំងពីក្នុងរជ្ជកាលព្រះបាទកោណ្ឌញ្ញជយវរ្ម័ន មាននាមវង្ស "ហៅថា" កម្ពុជវង្ស ទ្រង់មានព្រះទេវី ព្រះនាមដូចម្ដេច មិនប្រាកដ តែមានព្រះរាជឱរសសំខាន់ ២ អង្គ ព្រះនាម ភវវរ្ម័ន ១ មហេន្ទ្រវរ្ម័ន ឬហៅថា ចិត្តសេន ១ ។

កាលព្រះវីរវរ្ម័នសុគតទៅហើយ ព្រះភវវរ្ម័ន ឱរសប្យង៍ក៏បានទទួលសោយរាជសម្បត្តិ ក្នុងដំណែងជាចុងរាជតមក តែក្សត្រិយ៍អង្គនេះជាអ្នកក្លាហានក្នុងការរណរង្គ ។

កាលព្រះបាទស្រីសូរ្យវរ្ម័នទៅតាំងព្រះរាជធានីនៅបាងោម ក៏កើតបះរស៊ីគ្នាកើតជាសង្គ្រាមក្នុងប្រទេសឡើង ដោយព្រះភវវរ្ម័នជាអ្នកលើកមករាយមុន សឹងមានព្រះអនុជមហេន្ទ្រវរ្ម័នជាអ្នកជំនួយ ផលនៃការសង្គ្រាមក្នុងទីបំផុត ព្រះភវវរ្ម័នមានជ័យជំនះ បានគ្រប់គ្រងផែនដីទាំងមូល ក្នុងកាល ព. ស. ១១០៨ ទ្រង់មានព្រះអគ្គមហេសី ព្រះនាមកពីទ មានព្រះរាជឱរស ព្រះរាជធីតា ឬទេ មិនប្រាកដក្នុងប្រវត្តិសាស្ត្រនោះ ។

ការផែនដី ព្រះបាទភវវរ្ម័ន កាលទ្រង់បានគ្រងពិភពផែនដីទាំងមូលហើយ ទ្រង់បានចេញព្រះរាជប្រកាសឲ្យហៅជាតិខ្មែរថា "កម្ពុជា" នាមនេះមានអត្ថវិគ្គហៈថា «កម្ពុជា សុវណ្ណកោឯ ជិជន្តុ[១] តស្ស ហោហារតោតិ កម្ពុជ» ថែបថា "ជនពួកណារុងរឿងដោយមាស ជនពួកនោះឈ្មោះថា កម្ពុជា ពួកអ្នករុងរឿងដោយមាស" ទាំងឈ្មោះប្រទេសដែលធ្លាប់ហៅ ភ្នំ មកអំពីដើម ក៏ទ្រង់ប្រកាសឲ្យហៅថា កម្ពុជា ដែរឲ្យស្របគ្នានឹងឈ្មោះជាតិ ។ ដូច្នេះ គប្បីដឹងថា ជាតិខ្មែរ និងប្រទេសខ្មែរ បាននាមថា កម្ពុជា ពីត្រឹមរជ្ជកាលព្រះបាទភវវរ្ម័នទី ១ មក ។

---

១ ឧជធាតុ ប្រែត្រង់ក្នុងអត្ថថា រុងរឿង ។

ចំណែកខាងចិនដែលធ្លាប់ហៅប្រទេសខ្មែរថា ហ្វូណាន តាំងពីដើមមក ក៏បានផ្លាស់ហៅទៅតាមឈ្មោះថ្មី តែហៅមិនច្បាស់ថា ចិនឡា (កម្ពុជា) តាំងពីក្នុងរជ្ជសម័យនេះ ដូចមានប្រាកដក្នុងពង្សាវតារចិនស្រាប់ៗ

## សាងព្រះនគរភវបុរៈ

កាលរៀបចំប្រទេសឲ្យបានសាន្តត្រាណហើយ ព្រះបាទភវវរ្ម័នទ្រង់ទុកឲ្យព្រះមហេន្ទ្រវរ្ម័នឲ្យនៅគ្រងក្រុងស្រេស្ឋបុរៈ ក្នុងដំណែងជាឧបរាជ ហើយស្តេចចេញទៅសាងព្រះរាជធានីថ្មីនៅតំបន់ព្រៃនគរ ហៅថា "ភវបុរៈ" ។ ស្តេចគង់នៅក្រុងថ្មីនេះ រហូតដល់សោយទិវង្គត ។

## ព្រះបាទមហេន្ទ្រវរ្ម័ន

ព.ស. ១,១២៨-១១៤៣, គ.ស. ៥៩៨-៦១០

កាលព្រះបាទភវវរ្ម័នទី ១ សោយទិវង្គតហើយ ព្រះអនុជាធិរាជមហេន្ទ្រវរ្ម័នបានឡើងសោយរាជ្យ ស្តេចគង់នៅក្រុងស្រេស្ឋបុរៈដដែល, ទ្រង់មានព្រះអគ្គមហេសី ព្រះនាម មហេន្ទ្រទេវី ជាធីតាព្រះនាងសរស្វតី នឹងវិស្វរូប មានព្រះរាជឱរសដែលប្រាកដព្រះនាម ១ អង្គគឺព្រះរាជេន្ទ្រវរ្ម័ន ដែលបានសោយរាជ្យក្នុងឆ្នាំ ព. ស. ១១៩៣ ។

ការផែនដី ការគ្រប់គ្រងផែនដីក្នុងរជ្ជកាលនេះបានប្រព្រឹត្តទៅដូចក្នុងរជ្ជកាលមុន ។

## សាងព្រះនគរសម្បុរៈ

ក្រោយដែលបានទទួលរាជាភិសេកហើយ ព្រះបាទមហេន្ទ្រវរ្ម័ន ស្ដេចទៅសាងព្រះរាជធានីថ្មី នៅតាមផ្លូវទន្លេមេគង្គ ហៅថា "សម្បុរៈ" ក្រុងនេះនៅមានព័ស្តុតាងនៅដល់សព្វថ្ងៃនេះ តែក្រោយមកគេហៅថា "សំបូរ" ទៅវិញ ស្ដេចទៅគង់នៅក្រុងថ្មីនេះ ដរាបដល់សោយទិវង្គត ។

## ព្រះបាទ ឦសាណវរ្ម័ន

**ព.ស. ១១៥៣-១១៧៣, គ.ស. ៦១០-៦៣០**

កាលព្រះបាទមហេន្ទ្រវរ្ម័នសោយទិវង្គតហើយ ព្រះឦសាណវរ្ម័ន (១) បានឡើងសោយរាជ្យតមក ព្រះមហាក្សត្រិយ៍អង្គនេះមិនដឹងជាតវង្សមកអំពីក្សត្រិយ៍អង្គណាជាប្រាកដ ទ្រង់មានព្រះអគ្គមហេសីព្រះនាមដូចម្ដេច នឹងមានព្រះរាជឱរសព្រះរាជធីតាប៉ុន្មានទេ មិនប្រាកដក្នុងប្រវត្តិសាស្ត្រនេះ ។

ការផែនដី : ការគ្រប់គ្រងផែនដីនៅប្រព្រឹត្តទៅស្មើដូចក្នុងរជ្ជកាលមុន ៗ ព្រះមហាក្សត្រិយ៍អង្គនេះ ទ្រង់ជាអ្នកគាប់អានព្រះពុទ្ធសាសនា ដោយប្រាកដសេចក្ដីនៅសិលាចារិកជាភាសាខ្មែរ ដែលទ្រង់ឲ្យចារិកទុកនៅនគរបុរី ក្នុងឆ្នាំ ម. ស. ៥៣៣ មានសេចក្ដីរាយ

---

១ តាមក្នុងព្រះរាជពង្សាវតារនៃរបស់ស្ដេចព្រះមហាបិកាទ្រង់ចំពន្ធក្នុងពេលថ្មី ៗ នេះថា ព្រះឦសាណវរ្ម័ន ជារាជឱរសរបស់ព្រះបាទមហេន្ទ្រវរ្ម័ន(?) ។

ភប់មុខរបស់ផ្កាយដែលទ្រង់បានថ្វាយជាពុទ្ធបូជានៅទីក្រុងចាស់នោះ នឹងថា ទ្រង់តែងធ្វើសង្គ្រាមរាល់ៗថ្ងៃស័ល ។

គួរកំណត់សំគាល់ថា ព្រះមហាក្សត្រិយ៍អង្គនេះ ទ្រង់បានចារឹកភាសាខ្មែរទុកនៅផែនថ្ម មុនក្សត្រិយ៍អង្គឯទៀតទាំងអស់ ។

# សាងព្រះនគរត្បៀសាណបុរៈ

ព្រះបាទត្បៀសាណវរ្ម័ន បានស្ដេចទៅសាង ព្រះរាជធានីថ្មីនៅស្ទឹងសែនហៅថា "ត្បៀសាណបុរៈ" ហើយស្ដេចទៅគង់នៅក្រុងថ្មីនេះ ដរាបដល់សោយទីវង្គត ។

មកដល់ចុងរជ្ជកាល ក្នុងឆ្នាំ ព. ស. ១១៧០ (គ. ស. ៦២៧) ទ្រង់បានតែងរាជទូត ឲ្យនាំព្រះរាជសារទូលរាជបណ្ណាការ ទៅសុំចងសម្ពន្ធ-មេត្រីភាពនឹងស្ដេចចិន ។ ឯស្ដេចចិនក៏ព្រមទទួលនឹងតែងរាជទូត ឲ្យនាំព្រះរាជសារទូលរាជបណ្ណាការមកតបវិញក្នុងឆ្នាំនោះ ។ ប្រទេសខ្មែរបានចងសម្ពន្ធមេត្រីភាព នឹងប្រទេសចិន ជាគ្រាទី ៥ ក្នុងរជ្ជកាលនេះ ។

## ព្រះបាទភវវរ្ម័ន ទី ២

ព. ស. ១១៧៣ - ១១៩១, គ. ស. ៦៣០ - ៦៣៨ -

ព្រះមហាក្សត្រិយ៍អង្គនេះ ប្រាកដតែព្រះបរមនាមក្នុងសេចក្ដីកត់ហេតុតែប៉ុណ្ណោះ ប្រវត្តិការណ៍ទាំងពួងបានសូន្យទៅជាមួយនឹងកាល

ដែលកន្លងទៅ ។ ទោះបីយ៉ាងណាក៏ដោយ ព្រះរាជអង្គនេះ គង់មានក្រសែលោហិតធ្លាក់ចុះមកអំពីព្រះបាទភវវរ្ម័នទី ១ ។

## ព្រះបាទជយវរ្ម័ន ទី ១

ព. ស. ១១៨១[១] - ១១៨៣, គ. ស. ៦៣៨ - ៦៤០

ប្រវត្តិសាស្ត្រក្នុងរជ្ជកាលនេះបានសូន្យទៅជាច្រើន, ទើបមានព្រះអគ្គមហេសីព្រះនាមដូចម្តេច មានព្រះរាជឱរស ព្រះរាជធីតាប៉ុន្មាន មិនប្រាកដ ប្រាកដតែក្នុងរជ្ជកាលនេះ មានអសន្តិសុខជាញឹកញយ គឺមានការបះបោរ និងកើតសង្គ្រាមក្នុងប្រទេសជាច្រើនលើក ទោះបីដូច្នោះ ព្រះបាទជយវរ្ម័ន ទី ១ ទ្រង់ក៏ប្រឹងតស៊ូ រក្សារាជបល្ល័ង្កទុក រហូតមកដល់ឆ្នាំ ព. ស. ១១៨៣ ។

---

១ ក្នុងឆ្នាំដែលព្រះបាទជយវរ្ម័ន ទី ១ សោយរាជ្យ កើតមានសករាជ ១ យ៉ាង ដែលហៅថា ចុល្លសករាជ គេតាំងឡើងក្នុងឆ្នាំកុរ ព. ស. ១១៨១ ម. ស. ៥៥៣ ហើយរាប់ឆ្នាំកុរនោះជា ឯកស័ក ទំនៀមរាប់ស័កខ្មែរថា ឯកស័ក ទោស័ក ។ល។ នពស័ក សម្រិទ្ធិស័ក ក៏ចាប់មានប្រើឡើងជាមួយនឹងឆ្នាំកំណើតនៃចុល្លសករាជនេះ ។ ការតាំងចុល្លសករាជនេះ ដោយកំណត់យកដំណើរគោចរនៃព្រះអាទិត្យ ត្រង់វេលាដែលវិលខួបផ្ទួបចូលមកកាន់មេសរាសីវិញ គឺត្រូវត្រង់ថ្ងៃទី ១៥ ខែមេសា ជាកេណ្ឌ ។

សករាជនេះ អ្នកណាតាំងឡើង ប្រាកដតាមដែលបានស្រាវជ្រាវមកហើយ គឺក្សត្រិយ៍មានព្រះនាម សង្ឃរាជ ឬហៅ បុញសោរហ៊ន ជាក្សត្រិយ៍ ទី ១៩ ក្នុងវង្ស សមុទ្រឫទ្ធិ ទ្រង់តាំងឡើង តែក្នុងព្រះរាជពង្សាវតារក្រុងកម្ពុជា ដែល ម- ឌូដាដឺឡាក្រេ រៀបរៀងថា ពញាក្រែក ក្សត្រិយ៍ខ្មែរ ទ្រង់តាំងឡើង ហើយថាពញាក្រែកនោះសោយរាជ្យ នឹងគង់នៅក្រុងនគរធំ បើយើងពិនិត្យមើលកំណើតក្រុងនគរធំ ក៏នឹងឃើញថាក្នុងរវាងសករាជប៉ុណ្ណោះ គេពុំទាន់បានសាងនៅឡើយ ។

## ព្រះបាទជ័យវរ្ម័ន ទី ១

ព. ស. ១១៩៣ - ១២២៣, គ. ស. ៦៥០ - ៦៨០

ព្រះមហាក្សត្រិយ៍អង្គនេះ ជាព្រះរាជនុវង្សនៃព្រះបាទមហេន្ទ្រវរ្ម័ន ទ្រង់បានសោយរាជ្យគង់វ័យជាបន្តិចហើយ ទ្រង់មានព្រះអគ្គមហេសី ព្រះនាមដូចម្តេច នឹងមានព្រះរាជនុវង្ស ព្រះរាជធីតាឬទេ មិនទាន់បានប្រទះដំណឹងជាពិតប្រាកដ ។

ការផែនដី ៖ រឿងរ៉ាវផែនដីក្នុងរដ្ឋកាលនេះ បានរលាយសូន្យទៅជាមួយនឹងកាលដែលកន្លងទៅយូរហើយ នៅមានសល់ដំណឹងខ្លះតែខាងសាសនា ។ ការព្រះសាសនាប្រាកដថា ទ្រង់រាប់អានលទ្ធិសៃវៈ មានសេនាបតី ១ នាក់ ជាអ្នកសាងទេវស្ថានថ្វាយសម្រាប់ព្រះមហាក្សត្រិយ៍អង្គនេះ សាងវត្តខាងព្រះពុទ្ធសាសនាសម្រាប់ខ្លួនឯង ។

## ព្រះបាទបុស្ករ

ប្រមាណ ព. ស. ១២២៣ - ១២៦៣, គ. ស. ៦៨០ - ៧២០

ព្រះរាជាអង្គនេះ មិនដឹងជាពាក់ទងមកពីព្រះរាជវង្សណា វេលាដែលទ្រង់សោយរាជ្យនោះ ទ្រង់គង់នៅអនិន្ទិតបុរៈ ។ រឿងរ៉ាវទាំងពួងបានសាបសូន្យទៅអស់ ។

## ព្រះបាទបុស្ករាក្ស

ព្រះមាណ ព. ស ១២៦៣ - ១២៩៣, គ. ស. ៧២០ - ៧៥០

ព្រះរាជាអង្គនេះ ប្រហែលជារាជនុវង្សព្រះបាទបុស្ករៈ ។ ប្រព្រឹត្ត

ការណ៍ទាំងពួងក្នុងរជ្ជកាលនេះ បានៈលាយសូន្យទៅអស់ដូចក្នុងរជ្ជកាលព្រះបាទបុស្ករៈ ។

## ព្រះបាទពាលាទិត្យវរ្ម័ន

ប្រមាណ ព. ស. ១២៩៣ ១៣៤៣ គ. ស. ៧៥០ ៨០០

ព្រះមហាក្សត្រិយ៍អង្គនេះ ស្តេចគង់នៅក្រុងឥន្ទ្របុរៈ នៅភូមិមៀន ជិតទន្លេធំសព្វថ្ងៃនេះ ។ ក្រុងនេះជាក្រុងថ្មី ប្រហែលជាសាងក្នុងរជ្ជកាលព្រះបាទពាលាទិត្យវរ្ម័ននេះឯង ។

## សង្គ្រាមជ្វាគ្រាដំបូង

ក្នុងរជ្ជកាលនេះមានដំណើរថា ទ័ពជ្វាសង្គ្រាមទឹកជ្វាដែលលុកលុយចូលមក ។

ជ្វាក្នុងវេលានោះ តាំងព្រះរាជធានីនៅស្រីវិជ័យ ក្នុងកោះសូមាត្រា ជាអ្នកមានអំណាចរាជសក្តិធំ បានរួបរួមយកកោះផ្សេងៗ ក្នុងប៉ែកអគ្នេយ៍នេះបានទាំងអស់ ហើយពង្រីកអាណាខែត្រចូលមកដល់ពាក់កណ្តាលដែនមាលយូ គឺមកទល់នឹងព្រំដែនប្រទេសកម្ពុជា ។ មិនតែប៉ុណ្ណោះ មកដល់ក្នុងឆ្នាំ ម. ស. ៧២៣ ចុងរជ្ជកាលព្រះបាទពាលាទិត្យវរ្ម័ន ជ្វាបានលើកទ័ពតាមផ្លូវដើងទឹកមកវាយប្រទេសកម្ពុជាពីខាងត្បូង វាយលុករហូតដល់ក្រុងឥន្ទ្របុរៈ ព្រះបាទពាលាទិត្យវរ្ម័ន ទ្រង់ទប់ពុំបាន ក៏គោងចុះ

ចាញ់ជ្វា ហើយនៅក្នុងអំណាចជ្វាក្នុងឆ្នាំ ម. ស. ៧២៣ ដល់ក្នុងឆ្នាំ ៧២៤ ។ ជ្វានឹងខ្មែរច្បាំងគ្នាគ្រានេះជាដំបូង ។

# សរុបសេចក្តី

១ – សម័យនគរភ្នំ ជាសម័យដំបូងដែលខ្មែរស្ថាបនាឥស្សរភាពឡើងក្នុងដែនដីនេះ សម័យនគរភ្នំកំណត់ចាប់ពីឆ្នាំ ព. ស. ៦៩៣ ដល់ ១៣៤៣ ផុត រួមប្រមាណ ៦៥០ ឆ្នាំ ។

ព្រះមហាក្សត្រិយ៍ទាំងឡាយក្នុងជាន់ដើម ក្នុងសម័យនោះតែងសព្វព្រះរាជហឫទ័យក្នុងការផ្សាយឥទ្ធិពល ពង្រីកព្រះរាជអាណាខេត្តចេញទៅ ដោយហេតុនេះ ព្រះរាជអាណាចក្រកម្ពុជាក្នុងសម័យនោះ ទើបមានអាណាខេត្តធំទូលាយជាងក្នុងសម័យណា ៗ ទាំងអស់ ដូចមានសំដែងអំពីព្រំប្រទល់ក្នុងរដ្ឋកាល ព្រះបាទកោណ្ឌញ្ញជ័យវរ្ម័នស្រាប់ តែមកដល់ចុងសម័យនគរភ្នំ ព្រះមហាក្សត្រិយ៍ទាំងឡាយថយព្រះតេជានុភាពចុះដោយលំដាប់ ព្រោះតែដូច្នេះហើយ ក្នុងចុងសម័យនគរភ្នំ ទើបមានការបះបោរ នឹងកើតសង្គ្រាមក្នុងប្រទេសជាញឹកញយ ស្មើរតែគ្រប់រដ្ឋកាល ព្រះមហាក្សត្រិយ៍នោះ ៗ រវល់តែក្រាបការបះបោរក្នុងប្រទេស មិនមានឱកាសនឹងពង្រីកព្រះរាជអាណាខេត្តចេញទៅដូចរដ្ឋកាលមុន ៗ ព្រះរាជអាណាខេត្តទើបមិនបានរីកធំទូលាយចេញទៅទៀត កុំថាឡើយដល់ទៅពង្រីកចេញទៅទៀត សូម្បីតែស្រុកចំណុះដែលធ្លាប់

មានមកស្រាប់ហើយ ក៏មិនអាចនឹងគ្រប់គ្រងរក្សាឲ្យគង់នៅបាន ចាប្បី
នឹងមិនបានរំឭកផុតទៅអំពីកណ្ដាប់ដៃខ្មែរក្នុងចុងសម័យនគរភ្នំនេះ មិន
ត្រឹមតែប៉ុណ្ណោះ លុះមកដល់ចុងក្រោយបំផុត ប្រទេសកម្ពុជាបានធ្លាក់ទៅ
ជាចំណុះផ្ទា ១ ពេល ដូចមានប្រាកដក្នុងប្រវត្តិសាស្ត្រក្នុងរជ្ជកាល ព្រះ-
បាទពាលាទិត្យវរ័ន្ធនោះស្រាប់ ។

២ — ព្រះមហាក្សត្រិយ៍ទាំងឡាយ ក្នុងសម័យនគរភ្នំច្រើនសព្វ
ព្រះរាជហឫទ័យផ្លាស់ព្រះរាជធានីចេញពីព្រះរាជធានីចាស់ ទៅសាង
ព្រះរាជធានីថ្មីៗទៀត ជាច្រើនអន្លើដោយហេតុនេះ ព្រះរាជធានីក្នុង
សម័យនោះ ទើបមានចំនួនច្រើន ដូចមានរាយឈ្មោះតទៅនេះ

១ — នគរភ្នំ ជាបឋមនគរ

២ — នគរវ្យាធបុរៈ

៣ — នគរបុរី ឬនគរអង្គបតី

៤ — នគរស្រីសូរ្យបុរៈ

៥ — នគរភវបុរៈ

៦ — នគរសម្ភុបុរៈ

៧ — នគរត្បៀសាណបុរៈ

៨ — នគរអនិន្ទិតបុរៈ

៩ — នគរឥន្ទ្របុរៈ ។ នគរឥន្ទ្របុរៈនេះហើយដែលក្នុង

ព្រះរាជពង្សាវតារក្រុងកម្ពុជាហៅថា "ឥន្ទបត្តបុរី" ។ ក្នុងព្រះរាជ-ពង្សាវតារច្បាប់ដែលនេះថា ព្រះមហាក្សត្រិយ៍ខ្មែរអង្គអាទិរាជ គឺព្រះថោង ទ្រង់សាងក្រុងនគរធំ ជាដំបូង ដោយមានពួកនាគមកជួយសាងផងនោះខុសស្រឡះ អ្នកសិក្សាប្រវត្តិសាស្ត្រមិនត្រូវជឿកាន់យកជាប្រមាណ ។

៣) ការសាងប្រាង្គ-ប្រាសាទក្នុងសម័យនគរភ្នំ មានចំនួនតិច ហើយប្រាង្គ-ប្រាសាទក្នុងសម័យនោះ មានសាងតែដោយឥដ្ឋ មានថ្មប្រកបខ្លះបន្តិចបន្តួច ចំពោះតែងមេទ្វារ-មេបង្អួចប៉ុណ្ណោះ ។ ប្រាង្គ-ប្រាសាទក្នុងសម័យនោះ បាក់បែកអស់ហើយ នឹងយកប្រាង្គ-ប្រាសាទណាមួយមកបង្ហាញឲ្យឃើញជាក់ស្តែងក្នុងវេលានេះពុំបាន សុំឲ្យអ្នកសិក្សាពិនិត្យមើលដំណែលប្រាង្គ-ប្រាសាទ ដែលមាននៅនគរបុរីជាដើមនោះចុះ ។ សិលាចារឹកក្នុងសម័យនោះក៏មានចំនួនតិច ចារឹកជាភាសាខ្មែរ មានតែក្នុងរជ្ជកាលព្រះបាទឦសាណវរ្ម័ន ក្រៅពីនេះ ច្រើនតែជាភាសាសំស្ក្រឹត ។

៤) ការសាសនា: ក្នុងសម័យនគរភ្នំ សាសនាក្នុងប្រទេសមាន ២ យ៉ាង គឺ សាសនាព្រាហ្មណ៍ នឹងព្រះពុទ្ធសាសនាលទ្ធិស្ថវីរៈ (ហ៊ីនយាន) តែប៉ុណ្ណោះ ព្រះពុទ្ធសាសនាលទ្ធិមហាយាន ពុំទាន់ផ្សាយមកដល់នៅឡើយ ។ ក្នុងសាសនាព្រាហ្មណ៍នោះ គេគប់អានព្រះហរិហារៈធ្ងន់ជាងព្រះដទៃទាំងអស់ ដូចមានរូបព្រះហរិហារៈក្នុងសម័យ

នោះ នៅសល់ជាព័ស្តុតាងដរាបដល់បច្ចុប្បន្ននេះ ។ ចំណែកឯទេពារក្ស (អ្នកតា) គេរាប់ព្រះកាឡីជាធំសំខាន់ជាងគេបង្អស់ ។

៥) ព្រះមហាក្សត្រិយ៍ទាំងឡាយក្នុងសម័យនគរភ្នំក្នុងជាន់ដើម ទ្រង់ផ្ចាតក្នុងផ្សូវរដ្ឋបសាសនោបាយជាបំផុត គឺទ្រង់ប្រសប់ក្នុងការសម្រុះសម្រួលប្រជាជនរវាងជាតិខ្មែរ នឹងជាតិជ្វា - ជាតិលក៏ឲ្យរួបរួមទៅជាជាតិតែ ១, ជាតិជ្វានឹងលក៏មិនដែលមានរឿងបះបោរតស៊ូនឹងព្រះបេស្តាបារមីដល់ម្តងសោះ មានក្បត់ផែនដីខ្លះ តែក្នុងពួកព្រះរាជវង្សខ្មែរ ឬអ្នកដែលទាក់ទាមដោយពួកនេះ . ដោយអំណាចលោភចេតនាចង់បានមកុដរាជ្យប៉ុណ្ណោះ ។

**ព្រះរាជពង្សាវតារសម័យនគរភ្នំចប់ចុះតែត្រឹមប៉ុណ្ណេះ ។**

---

របរថ្នាំ

# របស់នាងនេត្រ – ឡាំងសី

នៅភូមិបឹងកេងកង ឃុំលេខ ៦ ក្រុងភ្នំពេញ

រង្វាន់លេខ ១

( ត - ចប់ )

ដែលគេបោះត្រង់ក្អេងឲ្យមានប្រហោងប៉ុនម្រាមដៃ ហើយដងទឹកទៅស្រោចឲ្យហូរតាមចំណោះកូនក្អមនោះពេញៗ រណ្ដៅកូនថ្នាំ ៗ ពេលដាំកូនថ្នាំ គេមិនដែលដាំព្រឹកទេ គេដាំតែក្នុងពេលរសៀល ដើម្បីកុំឲ្យស្វាកកូនថ្នាំ ដាំហើយគេស្រោចទឹកព្រឹកល្ងាច ២–៣ ថ្ងៃទើបឈប់ បណ្ដាយឲ្យវាដុះតាមទឹកសន្សើម និងចំហាយព្រះអាទិត្យ ៗ កូនថ្នាំនោះវាសន្ទប់ក្នុងវេលាថ្ងៃ ស្រស់ប្រប្រៃក្នុងវេលាយប់ ហើយក៏ដុះធំថ្លោសឡើងតាមលំដាប់ គេដាំក្នុង ១ រណ្ដៅ ១ ដើម បើមានងាប់រណ្ដៅណាគេដូសវិញ ៗ ក្នុងចម្ការមួយៗ គេដាំច្រើនម៉ឺនដើម ៗ

តាមធម្មតាអ្នកធ្វើរបរថ្នាំ កាលគេដាំកូនថ្នាំហើយភ្លាមគេតែងឆ្លៀតដាំត្រសក់ស្រូវ ត្រសក់ផ្អែម ឪឡឹក ល្ពៅ តាមចន្លោះជួរកូនថ្នាំផង ៗ

## ៤ – ជ្រិជី

ដោយអំណាចដីកោះមានល្បាប់ល្អ ហើយពេលនោះជារដូវមានអាកាសត្រជាក់ កូនថ្នាំរហ័សដុះលូតលាស់ឡើងតាមលំដាប់ មិនយូរ

ប៉ុន្មានត្រឹម ១ ខែមានកំពស់លំបមាន់ ៗ តាមទំនៀមអ្នកធ្វើចម្ការថ្នាំ តាំងពីពេលដាំកូនថ្នាំដំបូង រហូតដល់កូនថ្នាំពេញជំទង់ បើមានស្បូវ-គ្រាស ឬ ទ្រុគ្រាស គេតែងយកស្លឹកទខ្យ ១ មែក ដោតត្រង់ក្បាលចម្ការ កណ្ដាលចម្ការ និងចុងចម្ការ ដោយគេជឿជាក់ថា គ្រាសកន្ទន់កូនថ្នាំពុំបាន ៗ កាលកូនថ្នាំមានកំពស់ក្រោមជង្គង់ គេតែងជំរះស្មៅជ្រុំដីពូនគល់ពល់ដើមដោយចបកាប់ ៗ តាំងពីពេលជ្រុំដីពូនគល់មក កូនថ្នាំល្អណាស់ ខ្ពស់រហ័សមានស្លឹកធំៗ ទទឹង ១ ចំអាម បណ្ដាយ ១ ចំអាមកន្លះ ក្នុង ១ ដើមៗ មាន ៩ ឬ ១០ ស្លឹក ៗ

## ៥ – ក្ដិចត្រួយក្រៀវខ្នែង

កាលកូនថ្នាំនោះធំខ្ពស់ដូចពោលហើយ ពេលនោះជាពេលត្រូវក្ដិចត្រួយ ដើម្បីឲ្យដើមថ្នាំមានស្លឹកក្រាស់ធំ និងបន្ទុះជ័រក្នុងស្លឹកកុំឲ្យមានរសជាតិល្វីងពេក ថ្នាំនោះកាលធំអស់ទំហំ មានដើមប៉ុនកដៃក្មេង កំពស់ពាក់កណ្ដាលខ្លួនមនុស្សចាស់ក៏មាន ត្រឹមកប្លិចក្បាលក៏មាន (ត្រង់នេះច្បាប់ដើមមានគូររូបដើមថ្នាំផង) កាលគេក្ដិចត្រួយហើយ មានធុះខ្នែងតាមគល់ស្លឹក កាលធុះខ្នែងឡើងប្រវែង ២ – ៣ ធ្នាប់ គេក្រៀវខ្នែងនោះចេញ ៗ កិច្ចក្រៀវខ្នែង គេក្រៀវរឿយៗ ក្នុងថ្នាំ ១ ដើមយ៉ាងយូរត្រឹម ៧ – ៨ ថ្ងៃគេក្រៀវម្ដងរហូតដល់ពេលបេះស្លឹកអស់ទើបឈប់ ៗ

## ៦– កាបស្លឹកនិងរៀបស្លឹក

ចុងខែមាឃឬដើមខែផល្គុន (មិនា - មារ្ស) គេតែងបេះស្លឹកក្រោមៗ ហៅថារះជើង ៗ ស្លឹកថ្នាំមាន ៣ ថ្នាក់គឺ ៣ សន្លឹក ក្រោមបង្អស់ហៅថា ថ្នាំជើង ៤ - ៥ សន្លឹកកណ្ដាលហៅថា ថ្នាំចង្កេះ ៣ សន្លឹកចុងបំផុតហៅថាថ្នាំចុងសន្លឹក ៗ ថ្នាំជើងជាថ្នាំខ្សោយមិនសូវឆ្ងាញ ថ្នាំចង្កេះខ្លាំងសមគួរ ថ្នាំចុងសន្លឹកខ្លាំងជាបំផុត ហើយឆ្ងាញ់ជាងគេ ៗ កាលបេះស្លឹកថ្នាក់ណា គេពិនិត្យមើល បើឃើញថាចាស់ឡើងក្រហមខ្មោចៗ ទាំងខ្នងសន្លឹកទើបគេបេះ ២ - ៣ សន្លឹកក្នុង ១ ដើម ដាក់ក្នុងដាលដែលត្បាញពីបម្រៀកឫស្សី មានកំពស់ទីងដម្រៅជាង ១ ហត្ថ ទំហំមាត់ជិត ២ ហត្ថកងមូល (ត្រង់នេះច្បាប់ដើមមានគូររូបដាលផង) ញាត់ពេញហើយ គេទូលនឹងក្បាលយកទៅផ្ទះ ឬទៅរោងហាន់ថ្នាំ អ្នកណាមានរទេះគោ គេបេះស្លឹកថ្នាំដាក់រទេះទឹមគោ (ត្រង់នេះច្បាប់ដើមមានគូររូបរទេះគោផង) យកទៅផ្ទះ ឬទៅរោងក៏មាន ៗ កាលបានស្លឹកថ្នាំទៅដល់រោងហើយ គេរៀបសន្លឹកថ្នាំតរជាត្របកៗ ដូចត្របកម្លូ មួយត្របកចំនួន ១០ ឬជាង ១០ សន្លឹក ហើយគេបត់ចុងសន្លឹកដាក់តម្រៀបទុកបន្ទុំ ៗ

## ៣ – បន្ទុំ

កាលគេរៀបស្លឹកថ្នាំរួចហើយ គេជញ្ជូនយកទៅបន្ទុំក្នុងជង្រុកដែល មានទីបិទបាំងក្នុងរោងឬក្រោមផ្ទះ ទំហំជង្រុកបណ្ដោយ ៥-៦ហត្ថ ទទឹង

៣ - ៤ ហត្ថ ដម្រៅ១ហត្ថ បិទបាំងដោយស្លឹកត្នោត ឬស្លឹកត្រែង ក្រាលកន្ទេលបបុះ ឬស្លឹកត្រែងពីខាងក្រោម ហើយរៀបដាក់ត្របកថ្នាំ មានគល់ចុះក្រោមជាជួរ ៗ កន្ទ១ ជួរជាង ១០ ត្របក គ្របកន្ទេលបបុះពីលើឲ្យហប់ យ៉ាងយូរត្រឹម ៣ - ៤ យប់ ស្លឹកថ្នាំក៏ទុំពេញទាំងដង្រែក មានសម្បុរលឿងទុំស្រស់ល្អ ៗ

## ៨ - ហាន់

កាលស្លឹកថ្នាំទុំស្រះល្អហើយ គេជញ្ជូនចេញពីដង្រែកយកមកសកទងគ្រប់ស្លឹកចេញ ហើយយកទៅហាន់ដោយគ្រឿងប្រដាប់អម្បាលនេះគឺ :

ក) – ផ្ទាញ់ឈើ មានមេបញ្ឈរកំពស់ ១ ហត្ថ ១ ចំអាម គេចោះប្រហោងកណ្តាលជារង្វង់វាងតង់ក្រពើ ទំហំជិត១ទោម មានទូកសណ្តកពីលើភ្ជាប់នឹងមេបញ្ឈរ គល់ទូកគេលកឲ្យមានសណ្តានក្បែងកង់ស្រទបចេក ផ្សារងបុងដូចជាកងទូកង មានបន្ទូលភ្ជាប់ពីទូកទៅទ្រនាប់ខាងក្រោម ទ្រនាប់មានបណ្តោយ ១ ហត្ថ ១ ចំអាម បន្ទា ៨ ធ្នាប់ ទោល ៣ ធ្នាប់ ផ្តេកពីក្រោមទូក គេហៅថាផ្ទាញ់ថ្នាំ ។ (ច្បាប់ដើមមានគូររូបផ្ទាញ់ផង) ។

ខ) កាំបិតដែក មានមុខធំស្តើងកងខ្នងបន្តិច ក្រាស់តែទ្រនុងខ្នង បណ្តោយផ្ទៃ ១ ចំអាមកន្លះ ទទឹងគល់ផ្ទៃ ៧ ធ្នាប់ ចុង ៥ ធ្នាប់ មៀនដែក

ប្រវែង ៣ ធ្នាប់ ដងឈើឬពីងពង់ប៉ុនកដៃក្មេង បណ្ដោយ ៥ ធ្នាប់ ។ (ច្បាប់ដើមមានគូររូបកាំបិតផង) ។

គ) ឈើសន្ទូត ធ្វើពីឈើល្អសមានសាច់ទន់ ប្រវែង ១ ហត្ថ ១ចំអាម ទំហំប៉ុនកំភួនដៃ ភ្នួ ៤ ជ្រុង ចុងមូលសម្រាប់សន្ទូតកាំបិតហាន់ថ្នាំ ។ (ច្បាប់ដើមមានគូររូបឈើសន្ទូតផង) ។

ឃ) ថ្ម គេរកថ្មគ្រាតប្រវែង ១ គក់ ទោល ៤ ធ្នាប់ បន្ទា ៥ - ៦ ធ្នាប់ ៤ ជ្រុងទ្រវែង សម្រាប់សំលៀងកាំបិតហាន់ថ្នាំ ។ (ច្បាប់ដើមមានគូររូបថ្មសំលៀងផង) ។

ង) កន្ទេលឬថែប ត្បាញពីដើមបបុះ បណ្ដោយ ៤ ហត្ថ ទទឹង ២ ហត្ថ ១ ចំអាម ។

របៀបហាន់ គឺគេមូរទទឹងស្លឹកថ្នាំដែលសកហើយ ២ - ៣ ត្របក ឲ្យណែនក្តន់ ស៊កបញ្ចូលតាមបណ្ដោយទូកផ្ដៅកន្ទេលធ្វើឲ្យលៀនចេញបន្តិច ទើបគេអន្ទុយខាងស្ដាំដៃឆ្វេងរុញរមូរថ្នាំ ដៃស្ដាំកាន់កាំបិតហាន់ ។

## ៩.- ហាល

របរថ្នាំ មានកិច្ច ២ យ៉ាង ដែលផ្ដាស់ប្ដូរគ្នាពុំបាន គឺប្រុសជាអ្នកហាន់ ស្រីជាអ្នកហាល ប្រុសហាន់បាន ១ ផ្ដៅ ស្រីកើបគំនរសរសៃថ្នាំនៅមុខផ្ដៅរបស់ប្រុសយកទៅហាលលើកន្ទេលឬថែប ។ របៀប

ហាលគឺ គេអង្គុយកាន់ផ្ដុំសរសៃថ្នាំដោយដៃស្ដាំ អូសពីឆ្វេងទៅស្ដាំ ធ្វើសរសៃថ្នាំឲ្យស្ដើងស្មើគ្នាពេញទាំងកន្ទេល ។ គេហាលក្នុងម្លប់ ហើយគេសែងទៅហាលថ្ងៃ ១ ថ្ងៃទាល់ល្ងាច ។

## ១០– យកសន្សើម

ថ្នាំដែលហាន់ហើយ គេតែងហាលថ្ងៃ ៣ ថ្ងៃ ហាលសន្សើម ៣ យប់ ឲ្យមានសម្បុរក្រហមទុំល្អ ដល់ថ្ងៃទី ៣ គេហាលថ្ងៃឲ្យស្ងួតស្រួយទើបគេកាត់បណ្ដោយសរសៃថ្នាំនៅលើកន្ទេល ដោយដែកកាត់ធ្វើពីដែកឆ័ត្រមានចុងសំប៉ែតមុខស្រួចៗ ប្រវែងជាង ១ ចំអាម មានមេទទឹង២ ចោះរន្ធស៊កដែកឆ័ត្រចំនួន ៥ ឬ ៦ ពត់ឲ្យងុបចុងបន្តិច ស៊កទៅក្នុងមេ ឃ្លាតពីគ្នា ៥ ធ្នាប់ មានដងឈើប្រវែង ២ ហត្ថ ១ ចំអាម (ត្រង់នេះច្បាប់ដើមមានគូររូបប្រដាប់សម្រាប់កាត់ថ្នាំផង ) កាត់ហើយគេត្រមួតទុក ដល់វេលាយប់ទើបគេជញ្ជូនទៅពាយយកសន្សើមឲ្យជោកល្អ ហើយគេត្រមួតទុកនៅក្រោមផ្ទះឬក្នុងរោងត្រៀមនឹងបត់ជាបាញ់ជាចៅ ឬ ជាក្រតេតទៅ ។

ទំនៀមអ្នកធ្វើថ្នាំនៅកោះអណ្ដែតតូច ស្រុកកងមាស កំពង់ចាម សម័យបុរាណ គេហាន់ ១ លើកហាលថ្ងៃ ៣ ថ្ងៃ ហាលសន្សើម៣ យប់ ហើយបត់ជាចៅជាបាញ់ឬក្រតេ ១ លើកៗ តាមលំដាប់ហាន់ ដល់ហាន់អស់ពីចម្ការក៏ស្រេចតែម្ដង ។

សម័យបច្ចុប្បន្ននេះ គេហាន់ ១ ថ្ងៃ ហាលតែ ១ ថ្ងៃ យកសន្សើមតែកន្ទះយប់ ហើយគេបាក់គរទុកតែសាច់ថ្នាំទេ ដោយយកស្លឹកត្រែងខណ្ឌ ១ សើៗ តម្រួតលើគ្នាជាគំនរជំខ្ពស់ លុះហាន់អស់ពីបម្ការកាលណា ទើបគេរើយកមកហាលថ្ងៃហាលសន្សើម ១ យប់ទៀត ហើយហាលថ្ងៃកាត់ដាក់សន្សើម ធ្វើជាប៉ៅឬក្រពើជាខាងក្រោយសរុបគ្នាតែមួង ។

## ១១ — បត់ជាបាញ់ឬប៉ៅ

កាលគេយកថ្នាំទៅលើកន្ទេល ដែលគេកាត់រួចទៅដាក់យកសន្សើម ឲ្យមានសាច់ទន់ល្អិតល្មមសមគួរហើយ គេតម្រួតទុកជាគំនរ ទើបគេយកសំពត់ ១ ផ្ទាំងធំហៅថា " សំពត់ជាន់ថ្នាំ " មកក្រាលពាសពីលើសាច់ថ្នាំ ជាន់ជ្រញ្ជាំឲ្យហាប់ល្អ ហើយទើបគេបត់ ៗ របៀបបត់ គេត្រឡប់រឹមសរសៃថ្នាំខាងសងខាង ម្ខាងប៉ុនកូនដៃតាមជួរដែលគេកាត់ប៉ុន ៥ ផ្នាប់ ទទឹងកន្ទេលនោះបត់ឲ្យទៅជាមានបន្ទាទទឹង ៣ ផ្នាប់ បណ្ដោយប្រវែងកន្ទេលថ្នាំ ហើយគេបត់បណ្ដោយឲ្យខ្លីទៅទៀត នៅតែប្រវែង ១ គក់ រួចគេជាន់បង្ហាប់ យ៉ាងនេះហៅថា "បត់ជាបាញ់ឬជាក្រពើ" ។ ម្យ៉ាងទៀតកាលដែលកាត់នោះ គេកាត់ទទឹងកន្ទេលផងបណ្ដោយផង ប្រវែង ១ តោម ៤ ជ្រុង ដល់ពេលបត់គេជាន់ឲ្យហាប់ដូចគ្នា ហើយគេបត់ត្រឡប់រឹមជុំវិញឲ្យខ្លីបណ្ដោយ ៤ ផ្នាប់ ទទឹងខាងធំ ៣ ផ្នាប់ ខាងតូច ១ ផ្នាប់យ៉ាងនេះហៅថា "បត់ជាប៉ៅឬជាដុំ" ហើយគេគរទុក ។ .

## ១២ – រៀបពូក ឬដាក់ជាល

ថ្នាំដែលគេបត់ជាបាញ់ ឬជាក្រពើហើយ គេតែងរៀបជាពូក គឺរៀបដោយពុម្ពឈើដែលមានក្ដារ ៤ ផ្ទាំង កំពស់ ១ ហត្ថ ១ ចំអាម ទំហំ ១ គត់ភ្ជាប់ជា ៤ ជ្រុង បោះកន្ទាស់ភ្ជាប់ ប្រមុំជ្រុងគ្នា ៣ ផ្ទាំង ទុក ១ ផ្ទាំង ឲ្យមានគន្លឹះដកចេញចូលបាន (គំនូរនេះច្បាប់ដើមមានគូររូបពុម្ពឈើ ៤ ជ្រុងផង) វេលារៀបថ្នាំគេយកក្ដារ ១ បន្ទះទ្រាប់ពីក្រោម ហើយគេអង្គុយលើជើងម៉ាឈើ ឬកៅអី ហើយយកក្រពើថ្នាំរៀប ១ ម្ដងៗ បាន ៤ - ៥ ស៊ើ គេយកក្ដារ ១ បន្ទះ ៤ ជ្រុងប៉ុនពុម្ព គ្រមាស់ប៉ុនម្រាមដៃ សង្កត់ពីលើ ហើយជាន់បង្ហាប់ម្ដង ដរាបដល់ពេញពុម្ពទើបគេដកគន្លឹះហូតពុម្ពចេញ នៅតែថ្នាំទទេ បាន ១ លើកគេហៅថា ១ ពូក ឬ ១ គុប ។ ក្នុង ១ ពូកៗ មានទម្ងន់ចំនួនពី ១៥ ទៅ ២០ គីឡូក្រាម លុះដកពុម្ពចេញហើយ គេយកស្លឹកក្ដុល ២ សន្លឹក ចងតាមបញ្ឆៀរពូកថ្នាំនោះ ២ អន្លើ ហើយរៀបគ្របបិទបាំងទុកទៅ (គំនូរនេះច្បាប់ដើមមានគូររូបរបៀបពូកចងថ្នាំផង) ។ ថ្នាំដែលគេបត់ជាប៉ៅ ឬជាដុំ គេដាក់តម្រៀបក្នុងជាលត្បាញពីឫស្សី ទំហំទឹងជម្រៅ ១ ហត្ថ ១ ចំអាម ៤ ជ្រុង (គំនូរនេះច្បាប់ដើមមានគូររូបជាលសម្រាប់រៀបថ្នាំផង) បានមួយលើកៗ គេហៅ ១ ជាល ក្នុង ១ ជាលៗ មានទម្ងន់ដល់រយគីឡូក្រាមក៏មាន ។ កាលរៀបពូកឬ

ដាក់ផាលបានច្រើនហើយ បើមានឈ្មួញមកឲ្យថ្លៃត្រូវចិត្តគេក៏លក់តាមត្រូវការ ៗ ក្នុងឆ្នាំ ១៩៤៨ ថ្នាំទម្ងន់ ១០០ គីឡូដំឡៃជាង ១.០០០ រៀល ។

## អំពីសេចក្ដីសប្បាយ

របរថ្នាំក្នុង ១ រដូវមានពេលសប្បាយ ២ លើក គឺនៅពេលស្ទូងកូនថ្នាំម្ដង ពេលហាន់បានស្រេចដាំថ្នាំហើយម្ដង ដោយពេលស្ទូងដែលកូនថ្នាំល្មមដកយកទៅដាំ អ្នកដាំថ្នាំដែលគេមិនបានសាបស្ទូង គេយកម្ហូបចំណីនំផ្លែឈើច្រើនមុខមកដូរកូនថ្នាំយកទៅដាំ ។ ពេលហាន់អ្នកទន្លេឬអ្នកស្រែដែលមិនធ្វើថ្នាំ គេយកម្ហូបចំណីនំផ្លែឈើច្រើនមុខមកដូរថ្នាំ ។ នៅពេលនោះអ្នកធ្វើរបរថ្នាំសម្បូរម្ហូបចំណីប្រហែលផ្សារ ។

## សេចក្ដីបញ្ជាក់

របរថ្នាំ តាំងពីពេលសាបស្ទូង រហូតដល់ពេលហាន់ គេគ្រាន់តែមើលឫក្សថ្ងៃ នឹងរៀបសំណែន គឺស្លាធមិនឹងទៀនធូប នៅពេលដែលផ្ដើមសាបនឹងផ្ដើមដាំកូនថ្នាំ ដូចពោលហើយក្នុងថ្នាក់ទី ១ នឹងទី ៣ ប៉ុណ្ណោះ ឯត្រណមនឹងរឿងព្រេងគ្មានទេ ។

## ប្រយោជន៍

ថ្នាំជាគេសជ្ជៈម្យ៉ាង ដែលប្រជាជនគ្រប់ប្រទេសត្រូវការបរិភោគស្ទើរតែគ្រប់គ្នាជារឿយៗ ។ ថ្នាំតាមទំនើងក៏ ជារបស់ទុកមិនស្អូវបាន

យូរទេ តាំងពីហាន់បានជាសាច់ថ្នាំហើយ ទុកបានតែត្រឹមជាង ១ ឆ្នាំឡើងទៅ ក៏មានដង្កូវបុប្រុយស៊ី បើទុកដល់ ២-៣ ឆ្នាំទឹងខូច ប្រើការបរិភោគពុំបាន ប៉ុន្តែអាចធ្វើជាដីដាក់ដំណាំម្រេចតទៅទៀតបាន ដែលជាការងាររបស់អ្នកស្រុកកំពត ។

## ឈ្មោះអ្នកតែង

នាងនេត-ឡាំស៊ី នៅភូមិបឹងកេងកង-ឃុំលេខ ៦ ក្រុងភ្នំពេញ តែងដោយបានសួរបញ្ជាក់ឈ្មោះ អ៊ុក-ឡុង ជាបងថ្លៃ នៅភូមិអន្លង់ស ឃុំតាមដីកង ស្រុកកងមាស ខេត្តកំពង់ចាម ដែលជាអ្នកធ្លាប់ធ្វើបរថ្នាំយ៉ាងស្ទាត់ជំនាញ ។

នាងនេត-ឡាំងស៊ី

(3)



---

## ចិត្តវគ្គ (ត)

៥៨ – អ្នកមានទ្រព្យច្រើនមិនចេះចាយ ភរិយានៃបកាយមិនស្នេហ៍ស្និទ្ធ ធ្វើការក្រៃក្រៀមមិនពេញចិត្ត តុះទញ់គំនិតអស់ផ្លូវដើរ ។

៥៩ – ភរិយាមួយសុខស្រួលកាយចិត្ត ភរិយាពីរពិតដូចផេះផ្សំ ភរិយាបីដូចភ្លើងឆេះភ្នំ ភរិយាបួនសមអវិចិ ។

៦០ – ទ្រព្យធនមាសប្រាក់ឆាយកេរ្យា ជាតិស្រីកញ្ញាលំបាកថែ ចិត្តនៅឃ្វេងឃ្វាងយប់ថ្ងៃប្រែ គំនិតគេចកែមិនអាចស្គាល់ ។

៦១ – កុំឲ្យទុកចិត្តមិត្តយូរកាល ពួកសត្វបាលមហាពជ ទាំងស្រីគ្រឹហាក្រោមអំណាច នេះពាក្យអ្នកប្រាជ្ញប្រដៅទុក ។

## បកិណ្ណកវគ្គ

១ – អ្នកធំកុំប្រមាថអ្នកតូច ស្មៅល្វិវេញគួបចងដំរី ស្តេចពឹងរាស្ត្រសង្ឃវិន័យ មច្ឆាផលស័យពិតពឹងទឹក ។

២ – ធ្វើស្រែលើទួល សាកសួរទំនួល មនុស្សល្ងង់ល្ងិតយប់ ទីពឹងអសប្បុរស បានទុក្ខទោសសត្វ បណ្ឌិតសេពគប់ បានសុខសួស្តី ។

៣ – ខ្លួនគត់មាសប្រាក់ចង់ក្តី ចង់បានសេរីឥតរាសនា ឥតអាវុធមុតចង់ពុះពារ ខ្លួនជិតមរណាកេតុខ្លោ ។

៤ – គេមិនត្រូវការ តាំងចូលអាត្មា មើលការខុសត្រូវ ត្រួតត្រាឯកឯង សុខស្រួលគ្រប់ផ្លូវ បើគេមិនហៅ ខ្លួនទៅមិនគួរ ។

៥ – បើចុះធ្វើការធ្វើឲ្យអស់ចិត្ត ចាញ់ឈ្នះជាក់ពិតទើបពេញ អង្គប្រុស បើជាបរាជ័យចាញ់គេចុះ ឲ្យតែប្រឹងពុះពារគង់បានការ ។

៦ – រុក្ខជាតិឫសធំជាក់មាំជ្រៅ ខ្យល់ព្យុះសំដៅមិនបានការ ពូជស្មៅដើងក្រាសជាប់បន្ទា មុតរបាការរងទុក្ខធំ ។

៧ – ត្រូវយកដើមត្រែងជាច្បាប់ប្រាណ រាំយោបក់ប្រាណមិនរលំ រុក្ខជាតិមានយ៉ាងធ្លឹកស្រុក ខ្យល់ធំបក់បំគង់រលើង ។

៨ – ផ្ទះមានឆ្កែកាចគេខ្លាចក្រែង ប្រទេសគេស្ញែងមានបុរសរតន៍ ផ្លូវមានបន្លាខ្លាសន្ធត អ្នកដើររមត់មិនប្រមាទ ។

៩ – ចូលក្នុងសាលា កូនចៅខេមរ ត្រូវខំរៀនសូត្រ ក្មេងចាស់ក៏រៀន ស្តេចមន្ត្រីសោត ប្រឹងរៀនកុំឆោត ទាំងប្រុសទាំងស្រី ។

១០ – តារាសាស្ត្រមិនអាចស្គាល់ផ្កាយអស់ ភូមិសាស្ត្រសោះមិនស្គាល់ភូមិគត ប្រវត្តិសាស្ត្រមិនស្គាល់ស្តេចសព្វគ្រប់ ចេះផ្លូវលោកសព្វធម៌មិនយល់ ។

១១ – សេពគប់បណ្ឌិតដូចចន្ទន៍ក្រឹស្នា ក្រអូបអាត្មាក្លិនឈ្ងុយឈ្ងប់ ដូចជាតិស្ករផ្អែមធ្វើនំសព្វ រសជាតិប្រាថ្នាឆ្ងាញ់ពិសា ។

១២ — សេពគប់ជនពាលដូចម្ហូបស្អុយ ចេញចំហាយហុយ ស្អុយស្អុកខ្ទប់ អ្នកផងមិនត្រូវចូលសេពគប់ ក្រែងអប់ក្លិនអសោចិ៍ ស្រោចអាត្មា ។

១៣ — ត្រៃលោកជាប្រទីបត្រៃលក្ខណ៍ ជាតិភ្លឺច្បាស់ជាក់ផ្លូវ សាសនា សាងជាតិឲ្យមើលអតីតា អន្តរខេមកមហាអំណាច ។

១៤ — វិទ្យាសាស្ត្រសេដ្ឋកិច្ចប្រែលោកា ប្រែជាតិមនុស្សា ឧស្សា-ហកម្ម គ្រឿងយន្តបរមាណូប្រែទ្វីបប្រាំ នយោបាយមេនាំប្រែស៊ីវិល្ស័យ ។

១៥ — សង្ខារបង្កើតសង្កើចជិតមនុស្ស នៅក្នុងសាបស្មោះមាន ដង្កូវ មានជាតិក្រានៅក្នុងដើមស្រូវ នៅតាមព្រៃផ្លូវមានបន្លា ។

១៦ — បួសក្នុងសាសនាលះបង់ទ្រព្យ កូនប្រពន្ធសព្វគេហដ្ឋាន បួសក្នុងជាតិត្រូវប្ដូរអង្គប្រាណ ធ្វើចិត្តក្លាហានកុំខ្លាចស្លាប់ ។

១៧ — ជាតិជាកូនប្រុស ធ្វើទាហានស្មោះ និទ្រាលើពូក ធីប៉ាយក្រហម ជួយជាតិគោកធ្លក លីប៉ាវសាងលោក ស្លាប់ក្រោម ទង់ជ័យ ។

១៨ — ពេលមានតិចតួចស្ងប់ស្ងៀមពិត ប្រុសស្រីគួរគិតកសាង ជាតិ ឲ្យបានរឹងរឿងទើបហៅថ្លាត សង្វាតសាងលោកឲ្យក្រៀមក្រាន្ត ។

១៩ — កង្កែបនៅជិតកុម្ភឧប្បល មិនស្គាល់ជាតិឈ្ងុយក្លិនគន្ធា កន្ទង់នៅឆ្ងាយត្រេចត្រង់ផ្កា ជញ្ជប់រសាកេសរបាន ។

២០ – កុំដួសបាយក្តាំងបណ្តោញក្អៀរ ខបាយប្រចៀរគ្រាប់បរ ស្រីស្អាតមិនស្មើនឹងស្រីល្អ ជាតិអ្នកក្រអួតធំមានទាអាំង ។

២១ – ព្រឹក្សាឥតបុប្ផាមិនសោភ័ណ នគរខែត្រខ័ណ្ឌឥតនារី គ្រឹហាឥតក្មេងមិនសោភី ភរីឥតមច្ឆាមិនសោភា ។

២២ – ធ្វើសូមយាចក ថោកទាបអាក្រក់ ក្នុងនាលោកិយ ក្រទ្រព្យសម្បត្តិ មារយាទសោភី ទុកជាប្រុសស្រី រាប់មុខទុកចិត្ត ។

២៣ – ធម្មតារុក្ខជាតិដុះក្នុងផើង ចង់បានរុងរឿងដូចឈើព្រៃ មនុស្សថោកទាបល្ងង់ចង្រៃ ប្រាថ្នាចង់ថ្លៃដូចម្តេចកើត ។

២៤ – ធម្មតាជាតិដែលបញ្ញើក្អែក ទំលើទើរមែកឈើព្រឹក្សព្រៃ ផញ្ចប់យករសឥតប្រណី ទាល់តែក្សិណក្ស័យវិនាសបង់ ។

២៥ – មនុស្សមានប្រាជ្ញា មានតួដសោភា វិជ្ជាចំណេះ មារ-យាទឧត្តម សមចិត្តវិសេស ធ្វើការមិនធ្វេស កេរ្តិ៍ឈ្មោះល្បី ។

២៦ – បច្ចុប្បន្នសម័យមានរោងចក្រ រោងយន្តតាមថ្នាក់វិទ្យា-សាស្ត្រ អាកាសយានគ្រប់បែបប្រាជ្ញឈ្លៀវឈ្លាស គ្រប់សាស្ត្រស៊ីវិល័យទៅតាមកាល ។

២៧ – ចោរព្រៃហ៊ានដោយសារចោរស្រុក ខ្មោចក្រៅលុយលុកខ្មោចក្នុងញាំង មហាប្រទេសមិនហ៊ានចូលចម្បាំង បើមិនមានខ្មាំងក្នុងចិត្តក្បត់ ។

២៨ – មាតុភូមិដូចរុក្ខជាតិធំ មានម្លប់ត្រសុំសាយត្រជាក់ មានឫសចាក់ជ្រៅជាតំនាក់ ប្រុសស្រីចូលស្នាក់ស្រួលសប្បាយ ។

– (ន័យ) ម្លប់មាតុភូមិ ត្រជាក់ស្រួលល្ហែម ដល់ថ្លើមហឫទយា ប្រុសស្រីចូលជ្រក សុខស្រួលកាយា ត្រេកសោមនស្សា សប្បាយក្សេមក្សាន្ត ។

២៩ – ជីវិតិន្ទ្រិយ៍ទឹងហឫទយា សួតជាត្រីមុខទឹងមត្ថលុង្គ បើគ្រឿងចក្របារប្រែប្រួលខ្ចាំង អត្តភាពមិនតាំងនៅបានឡើយ ។

៣០ – បន្ទេនចង់លេបផែនដីអស់ មនុស្សអសប្បុរសចង់បានហួសខ្នាត ខ្លួនតូចកំសោយត្រួតលោកសង្វាត កាន់សីលមិនស្អាតចង់បាននិព្វាន ។

៣១ – បញ្ញាគេអាស្រ័យឲ្យត្រាប់កៀក ត្រាប់ជាងព្រួញលោកនយោបាយ ចម្រើនជាតិត្រាប់ប្រជាធិបតេយ្យផ្សាយ ប្រដៅសិស្សទាំងឡាយត្រាប់ស្ទួនផ្នាំង ។

៣២ – ការធ្វើបដិវត្តដល់ប្រទេស បើតាមប្រាជ្ញបេះនាំចំរើន ប្រែប្រួលទឹកដីចំរើន សញ្ញាត្រាប់លឿនទាន់កាលសម័យ ។

---

## ប្រជុំពាក្យពង្រឹងចរិយាភាព

លោកក៉យ - ប៊ុក ប្រៀបរៀង

**(តមក - ចប់)**

---

16— Dieu le veut —

Devise de Godefroy de Bouillon.

១៦— ព្រះជាម្ចាស់ ទ្រង់មានបំណងដូច្នោះ—

បាវចនា គូដឺហ្វ្រួយដឺប៊ុយយ៉ុង ។

17— Sans peur et sans reproche- —

Devise du Chevalier de Bayard.

១៧— ឥតខ្លាច, ឥតសៅហ្មង—

បាវចនា លោកមេទ័ពតាដឺ ដឺ បាយ៉ារដ៍ ។

18— Aut Cœsor aut nihil (ou César ou rien) —

Devise de César Borgia

១៨— ឬសេសារឬគ្មាន—

បាវចនា របស់សេសារបូស៊ីយ៉ា ។

19— Aplanos (Sans écart)—

Devise de la Famille de Monfmorency.

១៩ — ឥតយៀងឃ្លាត—

បាវចនា ករវង្ស ដឺ ម៉ុងម៉ូរ៉ង់ស៊ី ។

20— Cominus et Eminus (De près et de loin) -

Devise de Louis XII

២០ — ជិតនិងឆ្ងាយ-

បាវចនា មហាកដល្វី ១២ ។

21 — Plus ne m'est rien, rien ne m'est plus —

Devise de Valentine de Milan.

២១ — បើនពេកខ្ញុំក៏មិនត្រេកអរ, គ្មានសោះក៏ខ្ញុំមិនព្រួយ —

បាវចនា ព្រះនាងវ៉ាឡង់ទីន ដឺមីឡង់ ។

22 — A ma vie —

Devise de la ville de Reims.

២២ — កុំប៉ះពាល់ដល់ជីវិតខ្ញុំ (មានសត្វសំពោចជាសញ្ញា) —

បាវចនា នៃក្រុងរ៉ែមស៍ ។

23 — Servaborrectore Deo (Je serai sauvé par la main de Dieu) —

Devise de la ville de la Rochelle.

២៣ — ព្រះម្ចាស់ទ្រង់ជួយស្រោចស្រង់ខ្ញុំ ដោយព្រះហស្ត
របស់ព្រះអង្គ —

បាវចនា នៃក្រុងឡារ៉ូសែល ។

24 — Dignité, courage, discipline —
( emblème: tête d'éléphant avec 3 fleurs de lotus )

Devise du Parti Démocrate du Cambodge.

២៤ — ថ្លៃថ្នូរ, ក្លាហាន, វិន័យ —

បាវចនា គណៈបក្សប្រជាធិបតេយ្យកម្ពុជា (មាន
រូបក្បាលដំរីពាំផ្កាឈូកបីជាសញ្ញា) ។

25 — Perva sed virtuosa (Petite main courageuse) —

Devise de la ville de Mézières

២៥ — ដៃតូចក្លាហាន —

បាវចនា ក្រុងមេស៊ីយ៉ែរ ។

26 — Vérité, sincérité. équité ( emblème: une ruine ) —

Devise du Parti Libéral du cambodge.

២៦ - សច្ចៈ សុចរិត យុត្តិធម៌ (សញ្ញាៈ រូបប្រាសាទ)-

បាវចនា គណៈសេរីភាព កម្ពុជា ។

27 — Sans tache comme lui (emblème: un cygne)

Devise de la ville Du Blanc

២៧ - ឥតមានមន្ទិល ដូចជាសត្វនោះ (សត្វក្ងាន ជាសញ្ញា)-

បាវចនា នៃក្រុងប៊្លង់ ។

28 — Travail, Famille, Patrie -

Devise du maréchal Pétain.

២៨ - កិច្ចការ, គ្រួសារ, មាតុភូមិ-

បាវចនា ចមពល ប៉េតាំង ។

29 — Decus et Robur (Honneur et Force) -

Devise de la ville De Châlons

២៩ - កិត្តិយសនិងពលភាព-

បាវចនា នៃក្រុងដឺសាឡុង ។

30 — Tout le monde y travaille (emblème une ruche) -

Devise de la ville d'Elbeuf

៣០ - ជំនកល់គ្នា ត្រូវធ្វើការ (សញ្ញាៈ សំបុកឃ្មុំ) -

បាវចនា នៃក្រុងអេលប៊ឺហ្វ ។

31 - S'ils te mordent, mords les (emblème: lionet léapords) -

Devise de la ville de Morlaix.

៣១ - បើគេខាំយើង ត្រូវយើងខាំគេវិញ (សញ្ញាៈ រូបសិង្ហនិងខ្លាខិន)-

បាវចនា នៃក្រុង ដឺ ម៉រលេក្ស ។

32 — Plus penser que dire –
Devise de la ville de Bar-le-Duc

៣២– ត្រូវគិតឲ្យច្រើនជាងនិយាយ–
បាវចនា នៃក្រុង បា-ល៊ឺ-ឌុក ។

33 — Ny plus ny moins –
Devise de la Famille de Sales

៣៣– កុំច្រើនពេក កុំតិចពេក–
បាវចនា នៃត្រកូល ដឺសាល្ស ។

34 — Lilium inter lilia (Lis entre lis) –
Devise de Blanche de Castille

៣៤– បូរមើលសន្ទឹកបុប្ផាលិស–
បាវចនា ព្រះអង្គម្ចាស់ក្សត្រីប្លង់ដឺកាស្ទីយ ។

35 — Courte et bonne –
Devise de la Duchesse du Berry.

៣៥– ខ្លីហើយល្អ–
បាវចនា ព្រះអង្គម្ចាស់ក្សត្រីឌុយប៊េរី ។

36 — Fluctuat nec mergitur (Il flotte et ne sombre pas) –
(emblème: un vaisseau) –
Devise de la ville de Paris

៣៦– នាវាបើកលើគង្គា មិនដែលលិច (សញ្ញា: រូបនាវា)–
បាវចនា ក្រុងប៉ារីស ។

37 — Invenit et perfecit (Elle inventa et perfectionna) –
Devise de l'Académie des Sciences.

៣៧ – សភាវិទ្យាសាស្ត្រ តែងបង្កើត ទីងកៅ ប្រទេសបានល្អឡើង –

បាវចនា បណ្ឌិតសភាវិទ្យាសាស្ត្រ ។

38— Audaces fortuna juvat (La fortune aide les audacieux) —

Devise de Guillaume de Nassau le Taciturne.

៣៨ – ឆោគតែងជួយជនក្លាហាន –

បាវចនា ស្តេចគីយោមដឺណាស្សូឡឹតាស៊ីទួន ។

39— Lou souleu me fai canta (Le soleil me fait chanter) —

Devise du poète Mistral

៣៩ – ព្រះអាទិត្យធ្វើឲ្យខ្ញុំច្រៀង –

បាវចនា កវីនិពន្ធ មិស្ត្រាល ។

40— Sais—je ? –

Devise de Montaigne

៤០ – ខ្ញុំចេះឬ? –

បាវចនា ដឺ ម៉ុងតែញ ។

41— Vitam impendere vero (consacre sa vie au vrai) –

Devise de J. J. Rousseau.

៤១ – ត្រូវប្រើជីវិតខ្លួនស្វែងរកការពិត –

បាវចនា សង់សាក់រូស្សូ ។

42— Concordia, Industria, Integritas —

Devise de le Famille de Rothschild

៤២ – សាមគ្គី, ឧស្សាហ៍, យុត្តិធម៌ –

បាវចនា ត្រកូលដឺរូតស៊ីលដ៍ ។

43— Honneur et Patrie -

Devise de la Légion d'Honneur.

៤៣– កិត្តិយសនឹងមាតុភូមិ–

បារបនា មេដៃយ៍ លេស្យុងដូណើរ ។

44— Liberté et Patrie –

Devise de la Croix de Juillet.

៤៤– សេរីភាព នឹងមាតុភូមិ–

បារបនា គ្រឿងឥស្សរិយយសជុយ៉េត ។

45 – Valeur et Discipline—

Devise de la médaille militaire.

៤៥– ជំនៀ នឹងវិន័យ–

បារបនា, មេដៃយ៍ ទាហាន ។

46 · Si j'avance, suivez moi ; si je recule, tuez-moi ;— si je meurs, vengez-moi –

Devise de la Rochejaquelein.

៤៦– បើខ្ញុំទៅមុខ ឲ្យតាមខ្ញុំទៅ; បើខ្ញុំថយក្រោយ ឲ្យ សម្លាប់ខ្ញុំទៅ; បើខ្ញុំស្លាប់, ឲ្យសងសឹកជួសខ្ញុំ–

បារបនា ដឺឡារ៉ូស៊ីសាក់គឺឡាំង ។

47— Ne perdez point de vue mon panache blanc, vous le — trouverez toujours sur le chemin de l'honneur—

Devise de Henri IV.

៤៧– កុំភ្លេចក្រឡេកមើលស្លាបសត្វពណ៌សដែលដោតនឹងមួកខ្ញុំ, អ្នកមុខជាបានឃើញស្លាបសត្វនោះនៅលើផ្លូវប្រកបដោយកិត្តិយសជានិច្ច –

បារបនា ស្តេចហង់រីទី ៤ ។

48 — Satya Grihà -

Devise de Mahatma Gandhi

៤៨ – ការប្រកាន់ពាក្យសត្យ–

បាវចនា មហាត្មៈគន្ធីរ ។

49— Sattyam Nasti Paro Dharmah (Il n'y a pas — de religion supérieure à la vérité) (emblème: un serpent - mordant la queue)

Devise de la Société Théosophique de Madras (Indes).

៤៩ – សត្យំ នស្តិ បរោ ធម៌ៈ–

មិនមានសភាវៈអ្វីក្រៃលែងជាងពាក្យសត្យ (មានសញ្ញាៈ ពស់ខាំកន្ទុយ)–

បាវចនា នៃសង្គមសាសនា មទ្រ័ស (ឥណ្ឌា) ។

50— Par dessus les tombeaux, en avant

Devise de Gœthe.

៥០ – ត្រូវលោតរំលងផ្នូរខ្មោច (សេចក្ដីស្លាប់) ទៅខាងមុខ

បាវចនា របស់ ក៏ត ចិត្តសាស្ត្របណ្ឌិត, អាល្លឺម៉ង់ ។

51— Les académiciens penseront beaucoup, écriront peu et parleront le moins possible -

Devise de l'Académie silencieuse de Hamadan —

(Arabie)

៥១ – ពួកសភាបណ្ឌិត គិតច្រើន សរសេរតិចហើយនិយាយ តិចជាងនោះទៅទៀត–

បាវចនា នៃបណ្ឌិតសភាសម្ងាត់ នៅក្រុងហាម៉ាដង់

(អារ៉ាប់)–

52 – Je crains que le ciel ne tombe sur ma tête –

Devise des Gaulois.

៥២ – ខ្ញុំខ្លាចតែមេឃធ្លាក់មកលើក្បាលខ្ញុំ –

បាវចនា ពួកកូឡូ៉ ។

53 – Austrix est imperare orbi - universo ( A. E. I. O. U. )

Il appartient à l'Autriche de commander l'Univers.

Devise de la Maison d'Autriche

៥៣ – គួរឲ្យប្រទេសអូទ្រីសត្រួតត្រាលើសកលលោក –

បាវចនា សន្តតិវង្សអូទ្រីស ។

54 L'Amérique aux Américains –

Devise de Monroë.

៥៤ – ទ្វីបអាមេរិក ត្រូវបាន ទៅជាតិអាមេរិកាំង –

បាវចនា លោកមុង្រូអេ ។

55 – Scio cui crédidi (Je sais à qui je me suis confié) –

Devise de Pascal.

៥៥ – ខ្ញុំដឹងថាបុគ្គលណាដែលខ្ញុំត្រូវផ្ញើអាយុជីវិត –

បាវចនា ប៉ាស្កាល ។

(៦) ប្រវត្តិសាស្ត្រសង្ខេបប្រទេសឥណ្ឌា

ហ្វន់និពន្ធ មន្ត្រី ញ៉ុក-ថែម ប្រែ-រៀបរៀង

(តមក)

---

ព្រះមហាក្សត្រក្នុងរាជវង្ស យូអេជី សុទ្ធតែជាអ្នកកាន់ព្រះពុទ្ធសាសនា ហើយបានព្យាយាមចងស្ពានមេត្រីនឹងជាតិក្រិក នឹងធ្វើតាមបែបមហាក្សត្រក្រិក គឺទ្រង់នាំយកអារ្យធម៌របស់ក្រិកនឹងរបស់ព្រះពុទ្ធសាសនាមកផ្សំលាយគ្នា តែជនពួកនេះប្លែកជាងជាតិឯទៀតៗ មួយយ៉ាងគឺទទួលយកជាតិឥណ្ឌាមកជាជាតិខ្លួន រំលាយជាតិខ្លួនឲ្យទៅជាជាតិឥណ្ឌាសុទ្ធៗទៅ ។ ព្រះបាទកាតហ្វីសេស បឋមក្សត្រនៃរាជវង្សយូអេជីនោះគ្រងរាជសម្បត្តិជាវេលា ៤០ ឆ្នាំ គឺតាំងពីពុទ្ធសករាជ ៥១៣ មកដល់ ៥៥៣ បានពង្រីកអាណាចក្ររបស់ទ្រង់ចូលទៅក្នុងខែត្របញ្ចាបបាន ១ ចំណែក ។ អ្នកគ្រងរាជ្យបន្ទាប់មកតាំងអំពីពុទ្ធសករាជ ៥៥៣ ដល់ ៥៨៣ បានពង្រីកអាណាខែត្រទៅទៀត រហូតដែនបញ្ចាបចុះទៅដល់ទន្លេយមុនា ព្រះមហាក្សត្រអង្គទី ៣ ពង្រីកទៅទៀតរហូតដល់ក្រុងពារាណសី ។

លុះមកដល់ក្សត្រទី ៤ នៃរាជវង្សយូអេជីទ្រង់ព្រះនាមថា កនិស្កៈ គួររាប់ថាជាមហាក្សត្រយ៉ាងសំខាន់បំផុត ដែលមាននៅក្នុងរាជវង្សនេះ ហើយគ្រងរាជ្យបានដល់ ៣៣ ឆ្នាំ គឺតាំងពីពុទ្ធសករាជ ៦១៣ ដល់

ពុទ្ធសករាជ ៦៤៥ រាជអាណាចក្ររបស់ទ្រង់គួររាប់ថាធំក្រៃលែងឡើងច្រើន នៅក្នុងដែនអ៊ីរ៉ាន ជនពួកនេះមានអំណាចត្រួតត្រាដល់ខេត្តសុកដៀន, បាក់ត្រៀនទីងអារៀ ហើយនៅក្នុងឥណ្ឌៀបានគ្រប់គ្រងដែនគន្ធារៈ កស្មីរៈ បញ្ចាប, រហូតដល់ទៅស្រុកបាដលីបុត្រផង ៗ ទ្រង់បានតាំងទីក្រុងសម្រាប់រាជអាណាចក្រ នៅស្រុកបុរុសៈបុរៈ សម័យនេះហៅថាបេសាវ៉ារ ៗ ព្រះមហាក្សត្រអង្គនេះព្យាយាមធ្វើតាមយ៉ាងព្រះបាទអសោកមហារាជ គឺពិតតែទ្រង់មានរិទ្ធិអំណាចយ៉ាងធំក្រៃលែងយ៉ាងណាក៏ដោយ ទ្រង់នៅតែប្រកាន់ថា រាជកិច្ចសំខាន់របស់ព្រះអង្គនៅលើសាសនា ៗ

សាសនាជាប្រស្នាយ៉ាងសំខាន់ ក្នុងការគ្រប់គ្រងស្រុកទេសរបស់ក្សត្រឥណ្ឌៀគ្រប់ ៗ អង្គរៀងមក ជនជាតិឥណ្ឌៀមិនសូវបេះនឹករលឹកស្រឡាញ់ជាតិកំណើតរបស់ខ្លួនទេ ហើយទាំងមិនយកចិត្តទុកដាក់នឹងស្រុកទេសរបស់ខ្លួនផង តែមានរបស់មួយដែលជនជាតិយកចិត្តទុកដាក់ជាយ៉ាងក្រៃលែងតាំងអំពីកំណើតពង្សាវតាររហូតមកដល់ឥឡូវនេះ គឺរឿងសាសនា ៗ ឯព្រះមហាក្សត្រក្នុងរាជវង្សយូអេដអំពីដើម ៗ មកនោះអង្គខ្លះក៏ទំនុកបំរុងសាសនាព្រាហ្មណ៍ដំកល់ដំកើងព្រះរបស់ហិណ្ឌូ តែមកដល់សម័យព្រះបាទកនិស្កៈ ទ្រង់ទំនុកបំរុងព្រះពុទ្ធសាសនាយ៉ាងមុឹងម៉ាត់ដល់ទៅប្រកាសសម្រាប់ថាយកក្នុងរាជអាណាចក្ររបស់ព្រះអង្គ មានទាំង

ព្រះរូបរបស់ព្រះពុទ្ធជាម្ចាស់ផង ហើយទ្រង់បានកសាងវិហារសាលា និងព្រះស្តូបឡើងថ្មីៗ រាប់មិនអស់ ។

រាជ៍ពុទ្ធសករាជ ៦២៤ មានការប្រជុំធ្វើសង្គាយនាមួយទៀតនៅ ក្រុងបុរុសៈបុរៈ តែសង្គាយនាគ្រានេះខុសពីរបៀបសង្គាយនាកាលគ្រា ព្រះបាទអសោកមហារាជ គឺគ្រាព្រះបាទអសោកទ្រង់គ្រាន់តែចាត់ការ ផ្សាយសាសនាទៅទិសខាងត្បូង តែសង្គាយនាក្នុងគ្រានេះ បានតាំង បង្កើតជានិកាយមួយឡើងមានលទ្ធិប្លែកទៅទៀតហៅថា មហាយាន ហេតុដូច្នេះ ការប្រជុំធ្វើសង្គាយនានៅក្រុងបុរុសៈបុរៈនេះ ទើបគួររាប់ថា ជាកំណើតនៃលទ្ធិមហាយាន ដូចជាក្រុងបាដលីបុត្រជាកំណើតនៃលទ្ធិ ហីនយានដូច្នោះដែរ ។

តាមដោយពិត ជាវេលាយូរមកហើយ មុននឹងមានសង្គាយនា នៅក្រុងបុរុសបុរៈនេះ សេចក្តីយល់របស់ពុទ្ធសាសនិកជន បាន បែកខ្ញែកចេញទៅជា ២ ចំណែក ចំណែកខាងជើងមានសំណាក់ជាទី ប្រជុំធំនៅក្រុងកស្មីរៈ ហៅលទ្ធិរបស់ខ្លួនថា មហាយាន ដែលប្រែថា យានធំ ១ លទ្ធិប៉ែកខាងត្បូងហៅថា ហីនយាន ប្រែថាយានតូច ១ ទាំង២ចំណែកនេះមានយោបល់ខុសប្លែកពីគ្នា យោបល់ទាំងសងខាងតែង ខ្វែងទទឹងគ្នាជាដរាបមក លុះដល់មកមានការសង្គាយនានៅក្រុងបុរុសៈ-បុរៈនេះឡើង ទើបចាត់របៀបសាសនាជាបែបផែនតាមយោបល់ប៉ែកខាង

ជើង ដោយពួកនិកាយខាងត្បូងមិនយល់ព្រមផងឡើយ ព្រះពុទ្ធ-សាសនាទើបបែកចេញជាពីរនិកាយតាំងអំពីកាលនោះមក ។ គ្រានោះមានព្រះថេរៈ ១ អង្គឈ្មោះព្រះវសុមិត្រ ដែលជាប្រធានក្នុងការធ្វើសង្គាយនានៅទិសខាងជើងនោះ ត្រូវពួកព្រះមហាថេរៈនៅទិសខាងត្បូងលុបឈ្មោះពីបញ្ជីគណៈសង្ឃ តែលទ្ធិមហាយានដែលបានតាំងឡើងថ្មីនេះបានទទួលសេចក្តីទំនុកបំរុងអំពីព្រះបាទកនិស្កៈដោយល្អ កាលព្រះបាទកនិស្កៈទិវង្គតទៅហើយ មានព្រះមហាក្សត្រ ២ ព្រះអង្គទៀតទ្រង់ព្រះ-នាមថា ហុវិសកៈ គ្រងរាជសម្បត្តិក្នុងរវាងពុទ្ធសករាជ ៦៤៥ ដល់ ៦៧៥, ព្រះរាជា ១ អង្គទៀតទ្រង់ព្រះនាមថា វាសុទេវៈ ទ្រង់គ្រងរាជសម្បត្តិអំពីពុទ្ធសករាជ ៦៧៥ ដល់ពុទ្ធសករាជ ៧១៥ សុទ្ធតែទ្រង់បានទំនុកបំរុងលទ្ធិមហាយាន ឲ្យកាន់តែចំរើនក្រៃលែងឡើងទៅទៀត ។

ការដែលពុទ្ធសាសនាមានលទ្ធិបែកខ្ញែកគ្នាជាពីរនិកាយដូច្នេះ មុខគួរឲ្យស្តាយណាស់ ហើយមិនត្រូវនឹងព្រះបំណងរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់នឹងព្រះសាសនាសោះឡើយ តែការដែលព្រះរាជវង្សយូអេជីឧបត្ថម្ភទំនុកបំរុងនិកាយនេះ គេរាប់ថាជាផ្លូវចំរើនដល់ព្រះពុទ្ធសាសនាមួយយ៉ាងដែរ ព្រោះក្សត្រក្នុងរាជវង្សមានស្ពានមេត្រីទាក់ទងនឹងប្រទេសចិនជាច្រើនក្នុងសម័យដែលរាជវង្សយូអេជីគប់គ្រងឥណ្ឌានោះ ជាហេតុនាំឲ្យព្រះពុទ្ធសាសនាបានផ្សាយចូលទៅក្នុងប្រទេសចិន ជាដំបូង

គឺកាលកើតចម្បាំងរវាងចិននឹងអាណាខេត្រផ្សេងៗ ក្នុងទួរគីស្ថាននោះ ពួកទាហានចិនដែលលុកចូលមកក្នុងតំបន់អស់នោះ លុះដល់ត្រឡប់ទៅវិញបាននាំយកព្រះពុទ្ធរូបជាប់ទៅជាមួយផង ។ ព្រះមហាក្សត្រចិនទ្រង់ព្រះនាមមិងទី ដែលគ្រងរាជសម្បត្តិក្នុងរវាងពុទ្ធសករាជ ៦០១ ដល់ពុទ្ធ-សករាជ ៦១៨ នោះ ក៏កើតមានរាជបំណងចង់ឃើញលទ្ធិសាសនាថ្មីនោះ លុះការវិវាទទាស់ទែងគ្នាស្ងប់រំងាប់ហើយ ទើបទ្រង់សុំឲ្យខាងឥណ្ឌា បញ្ជូនសមណៈទូតឲ្យចូលទៅក្នុងស្រុកចិន ។ គ្រានោះ ព្រះមហាក្សត្រក្នុងរាជវង្សយូអេជីបានចាត់បញ្ជូនព្រះមហាថេរៈ ២ អង្គ ឈ្មោះមាតង្គៈ ១ អង្គ ឈ្មោះគោភារនៈ ១ អង្គ ហើយបាននាំយកគម្ពីរខ្លះជាប់ទៅជាមួយផង ដោយសារការបេះដូងនឹងការប៉ិនប្រសប់របស់ព្រះមហាថេរទាំង ២ អង្គ ជាហេតុធ្វើឲ្យព្រះបាទមិងទី ប្រកាសព្រះអង្គជាពុទ្ធមាមកៈ កាលពីពុទ្ធ-សករាជ ៦០៧ ហើយព្រះពុទ្ធសាសនាក៏ផ្សាយចូលទៅប្រតិស្ឋានក្នុងស្រុកចិន តាំងអំពីកាលនោះមក ។

ព្រះរាជវង្សយូអេជីនេះ គួរកប់ចារជារាជវង្សយ៉ាងធំនៃក្រៃលែងរបស់ឥណ្ឌា ដោយហេតុមិនបានធ្វើស្ពានមេត្រីទាក់ទងនឹងស្រុកចិនតែមួយទេ គឺបានចងស្ពានមេត្រីទាក់ទងគ្នាទៅដល់ទ្វីបឧរុបរហូតដល់ក្រុងរោមផង ។

ឯលទ្ធិមហាយាននឹងហីនយាន ដែលជាហេតុបែងចែកព្រះពុទ្ធ-សាសនាជា ២ និកាយនេះមានទំនងដូច្នេះ :

ព្រះពុទ្ធសាសនាប៉ែកខាងជើង ដែលបានប្រកាសផ្សាយចេញទៅខាងស្រុកកស្មីរៈនិងគន្ធារៈ ដោយអានុភាពរបស់ព្រះបាទអសោកមហារាជនោះ បានចូលប្រឡូកប្រឡល់នឹងអារ្យធម៌របស់ក្រិក ទើបកើតមានការប្រែប្រួលឡើងថ្មីទៀតជាច្រើន ៗ យើងបានដឹងមកហើយថា ពួកក្រិកគោរពបូជាព្រះច្រើនអង្គណាស់ ហើយព្រះអស់នោះសោតទៀត ក៏សុទ្ធតែប្រកាន់ថាសក្តិសិទ្ធិអាចនឹងបណ្តាលការអ្វីៗ ឲ្យបានសម្រេចដូចខ្លួនបានបន់ស្រន់សុំទាំងអស់ ទើបនាំឲ្យពុទ្ធសាសនិកជននៅដំបន់អស់នោះកើតគំនិតគិតឃើញថា កាលបើព្រះរបស់ក្រិកមានរិទ្ធិតេជះខ្លាំងពូកែដល់ម្ល៉េះបាន ម្តេចក៏ព្រះពុទ្ធជាម្ចាស់របស់យើងមានរិទ្ធិអំណាចខ្លាំងពូកែដូច្នោះមិនបាន, បើព្រះរបស់ក្រិកចាំជួយៈស្រោចស្រង់អ្នកដែលគោរពបូជាព្រះអង្គ ម្តេចក៏ព្រះពុទ្ធរបស់យើងជួយស្រោចស្រង់ពុទ្ធសាសនិកជនមិនបាន, ដូច្នេះហើយជាឲ្យមានយោបល់យល់ខុសប្លែកពីគ្នារហូតដល់គោលសំខាន់បំផុតរបស់ព្រះពុទ្ធសាសនាគឺពាក្យថា "និព្វាន" ៗ នោះគេសំដៅសេចក្តីដូចម្តេច ៗ តាមយោបល់ខាងហីនយានយល់ថាបានដល់ការរលត់កិលេសនឹងខន្ធទាំង ៥ ចំណែកខាងមហាយានយល់ថា, ព្រះពុទ្ធជាម្ចាស់មិនបានរលត់សូន្យទៅណាឡើយ ទ្រង់គង់ប្រថាប់នៅក្នុងកន្លែងណាមួយ ដូច្នេះហើយទើបជាហេតុឲ្យពួកមហាយានទុកព្រះ

ពុទ្ធជាម្ចាស់ដូចទេវតា ១ អង្គនៅស្ថានសួគ៌ ។ រឿងនេះហើយជាហេតុនាំឲ្យបង្កើតព្រះពោធិសត្វឡើង ។

ឯគម្ពីរដែលមាននៅក្នុងស្រុកយើងវេលានេះ ក៏មានរឿងរ៉ាវរបស់ព្រះពោធិសត្វជាច្រើន ហើយគប្បីយល់ថាព្រះពោធិសត្វនោះ មិនមែនកើតឡើងដោយគំនិតប៉ែកខាងយើងទេ គឺសុទ្ធតែខាងពួកមហាយានគិតឡើងទាំងអស់ ដូច្នេះហើយបានជាដែនដីទាំងឡាយ ដែលលទ្ធិមហាយានផ្សាយចូលទៅដល់ គឺក្នុងដែននេប៉ាល, ប្រទេសចិន, និងជប៉ុន ទើបនិយមរាប់អានព្រះស្រីអារ្យ៍គឺព្រះអរិយមេត្រៃយ ដែលជាព្រះខាងសេចក្ដីស្រឡាញ់, មេត្រី, ព្រះអមិតាភៈ ដែលជាព្រះម្ចាស់នៅស្ថានសួគ៌ទិសខាងកើត និងព្រះអវលោកិតេស្វរៈ ជាព្រះនៃសេចក្ដីករុណា ។ ក្រៅពីនេះនៅមានព្រះជាស្ត្រីកទៀត ព្រះនាមថាមាយា ដែលមាននាទីជាអ្នករក្សាសុខ-ទុក្ខ សេចក្ដីក្ដៅក្រហាយរបស់ពួកមនុស្ស ។ ព្រះនាងមាយាគឺព្រះពុទ្ធមាតា ក្នុងលទ្ធិមហាយានច្រើនតែធ្វើព្រះរូបគូបនឹងព្រះរូបរបស់ព្រះពុទ្ធជាម្ចាស់ជានិច្ច លទ្ធិមហាយានមានព្រះថេរៈសំខាន់ៗដទៃទៀតដូចមានឈ្មោះតទៅនេះ :

អង្គដំបូង គឺព្រះវសុមិត្រត្ថេរៈ ដែលជាអ្នកផ្ដើមធ្វើសង្គាយនាក្នុងផែនដីស្ដេចកនិស្កៈ ហើយបានប្រកាសតាំងលទ្ធិមហាយានឡើង កាលពុទ្ធសករាជ ៦២៤ ។ តមកៈ ព្រះអស្វឃោសត្ថេរកើតនៅស្រុកសាកេត

ជាគណាចារ្យមានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងដែនមគធៈ   តាមជំនឿរបស់
មនុស្សនៅដំបន់នោះនិយាយថា   ព្រះបាទកនិស្កៈទ្រង់លើកទ័ពចូលទៅ
ច្បាំងនៅដែនមគធៈ  ដោយទ្រង់ប្រាថ្នាខ្លួនលោកអស្វឃោសៈប៉ុណ្ណោះ ។
លុះបានលោកមកហើយ   ក៏តាំងលោកជាទីប្រឹក្សាខាងផ្លូវសាសនារបស់
ព្រះអង្គ   ហើយលោកអស្វឃោសនេះហើយដែលបានតែងរឿងពុទ្ធប្រវត្តិ
ជាពាក្យឆន្ទ   ដំបូងបង្អស់ឲ្យឈ្មោះថា ពុទ្ធចរិត  ហើយបានប្រែជាភាសា
ចិន   កាលពីពុទ្ធសករាជ ៩៥៣ ។

តពីនោះមក   មានព្រះថេរៈ ១ អង្គឈ្មោះនាគាជុនៈ  បានតែងគម្ពីរ
មិលិន្ទបញ្ហានិងគម្ពីរឯទៀតៗ   ហើយបានរៀបចំគោលចារិកដ៏ពិតប្រាកដ
សម្រាប់លទ្ធិមហាយាន   អំពីរឿងនិព្វានថា   និព្វាននោះមិនមែនជារបស់
សូន្យដូចយ៉ាងពួកមហាយានយល់នោះទេ   គឺថានិព្វានជាស្ថានមានរូប
អ្នកដែលទៅនិព្វានហើយ   ក៏នៅតែមានរូបនៅក្នុងទីណាមួយ   តែជា
រូបបរិសុទ្ធឥតមន្ទិលសៅហ្មង   ហេតុនេះឯងបានជាប៉ែកខាងមហាយាន
ទើបជឿថា   ក្នុងវេលានេះ   ព្រះពុទ្ធជាម្ចាស់ទ្រង់គង់នៅទីណាមួយជា
មិនខាន ។

លោកនាគាជុនៈមានសិស្សមកពីលង្កា១អង្គឈ្មោះថាទេវៈ   ក្នុងវេ-
លាតមកជាមហាថេរៈចាត់ជាអង្គទី ១៤   ។   ព្រះថេរអង្គនេះទូន្មានថា
ពាក្យសូត្រមន្តរបស់ពុទ្ធសាសនិកជន   តែងលាន់ឮរហូតទៅដល់អ្នកដែល
បែកស្ថានទៅហើយ   ព្រមទាំងព្រះពុទ្ធជាម្ចាស់ផង   ព្រះថេរអង្គនេះ

ហើយដែលជាអ្នកផ្សាយលទ្ធិ ដែលជាទីគោរពរាប់អានព្រះអមិតាភៈ ឲ្យមានផ្សាយចេញទៅក្នុងប្រទេសគេណ្ឋាឡើង ។

លទ្ធិមហាយានដែលបានតាំងឡើងជាឡាក់ឋាន ដោយព្រះថេរៈដែលព្យាយាមផ្សាយលទ្ធិនេះយ៉ាងម៉ឺងម៉ាត់ ៗ មកទៀតជាច្រើនអង្គ គឺ: ព្រះអសង្ឃៈ, ព្រះវាសុពន្ធ, ព្រះពុទ្ធសិមាហ, ឯព្រះអសង្ឃៈ នឹងព្រះវាសុពន្ធនោះជាបងប្អូននឹងគ្នាជាអ្នកគន្ធារៈ ។ កាលដើមឡើយលោកទាំង ២ អង្គនេះ នៅក្នុងនិកាយហីនយាន ព្រះអសង្ឃៈបានចូលមកកាន់លទ្ធិមុន ឯព្រះវាសុពន្ធនៅតែកាន់លទ្ធិហីនយាននៅឡើយ មានពង្សាវតារមួយអន្លើពោលទុកថា ថ្ងៃ ១ ព្រះអសង្ឃៈបានផ្តាំឲ្យព្រះវាសុពន្ធទៅជួបក្នុងវិហារមួយជិតស្រុកអយោធ្យា ហើយបាននិយាយប្រស្រ័យគ្នាតាមធម្មតា មិនបានដឹកនាំឲ្យប្អូនបែរមកកាន់លទ្ធិមហាយានទេ លុះបានបរិភោគអាហារ(១)រួចហើយ ក៏នាំប្អូនឡើងទៅលើមណ្ឌប១ខ្ពស់ ហើយនៅខាងមុខនោះមើលឃើញទន្លេគង្គា មានទឹកថ្លាយង់ មានពន្លឺរស្មីដួងព្រះចន្ទ្រចាំងមកចាប់ទឹកទន្លេគង្គាក្នុងយប់ថ្ងៃនោះ ។ ព្រះវាសុពន្ធអង្គុយនៅក្បែរបង្អួចកំពុងត្រិះរិះអ្វីមួយយ៉ាងស្ងប់ស្ងាត់ មានភិក្ខុ ១ រូបនៅខាងក្រោមកំពុងសូត្រធម៌យ៉ាងបែបមហាយាន ធម៌នេះហើយជាហេតុធ្វើឲ្យព្រះវាសុពន្ធកើតសេចក្តីជ្រះថ្លា ដល់ទៅទឹកភ្នែកហូរស្រក់ស្រោចមកពេញមុខ ។ តអំពីនោះមក ព្រះវាសុពន្ធក៏គោរពរាប់អានលទ្ធិមហា-

---

១ តាមលទ្ធិមហាយានថា លោកសង្ឃឆាន់អាហារវេលាល្ងាចបានមុនព្រះអាទិត្យលិច ។

យានយ៉ាងខ្ជាប់ខ្ជួន ហើយបានប្រកាសផ្សាយលទ្ធិនេះឲ្យកាន់តែរឹងប៉ឹង ចំរើនឡើងយ៉ាងខ្ជាប់ខ្ជួនរហូតមកដល់ក្រុងរាជគ្រឹះ ។ ព្រះវសុពន្ធបាន ទទួលជ្រើសរើសជាព្រះសង្ឃរាជទី ២០ ហើយលោកអនិច្ចធម្មនៅស្រុក អយុធ្យា ។

រាប់តាំងអំពីរាជព្រះពុទ្ធសករាជ ៩០០ ឆ្នាំមក ព្រះពុទ្ធសាសនាមិន បានចំរើនរីករាយណាស់ទេ តែក្នុងប្រទេសឥណ្ឌៀបានផ្សាយចេញទៅ ទិសខាងកើតយ៉ាងច្រើនគឺប្រទេសទួរគីស្ថាន, ស្រុកចិន, ស្រុកកោលី, ឥណ្ឌូចិន, និងក្នុងប្រទេសជប៉ុន ហើយនៅក្នុងរាជនេះ មានសមណៈ ចេញចូលទៅមកក្នុងរាជប្រទេសចិននិងឥណ្ឌៀជារឿយ ។ ហើយលទ្ធិ-មហាយានក៏ផ្សាយចេញទៅពាសពេញរហូតភាគធំនៃទ្វីបអាស៊ីនេះ ។

## វគ្គទី ៤

# ឥណ្ឌៀភាគកណ្ដាល - ព្រះបាទសីលាទិត្យ

កាលព្រះបាទកនិស្កៈទិវង្គតទៅហើយ ក៏មានក្សត្រជាដំណតព្រះ រាជវង្សតមកទៀត ២ អង្គ ក៏នៅតែទ្រទ្រង់មហាអំណាចនៅបាន តែកាល អស់បុណ្យព្រះមហាក្សត្រទាំង ២ អង្គនោះទៅ អំណាចរបស់រាជវង្ស យូអេជីក៏សាបសូន្យចុះទៅច្រើន នៅសល់ត្រឹមអាណាខេត្តគន្ធារៈ កស្មីរៈ (ក្នុងឥណ្ឌៀ) ហើយនិងប៉ាកត្រៀននិងតានសកដៀន (ក្នុងអ៊ីរ៉ង់) ។

(មានត)

# រឿងកោគកុលកុមារ

លោក ឧកញ៉ាព្រះឃ្លាំង ទង់ វៀបវៀង

(តមក)

ស្រះស្រីជាទីជាតជល - សាសាន្តសុខសល់ សម្រាប់ក្សត្រា ៗ
ព្រះឥន្ទ្រទេវិន្ទ្របង្គាំថា ចូរអ្នកនិទ្រា នៅទេះសម្រាន្ត ៗ ឈប់ស្ទុះនៅ
ទេះទីងមាន ស្រីទាំង៣ប្រាណ មកដងគង្គា ៗ ទៅស្រង់នូវអង្គធីតា
គឺនាងសុខុមា-លន្ទាកល្យាណ ៗ អ្នកនឹងបានដឹងពិតមាន ដៀងជាក់នឹង
បាន ជួបនឹងភរិយា ៗ ផ្គាំស្រេចសម្តេចឥន្ទ្រា ហោះទៅសួគ៌ា ទិព្វទី
លំនៅ ៗ កោគកុលនិម៌លតតសៅ ក្រោយព្រះឥន្ទ្រទៅ អ្នកចូលចុះ
ស្រង់ ៗ ក្នុងស្រះស្រៅជ្រះថ្លាយង់ ជម្រះព្រះអង្គ ជាសុខសប្បាយ ៗ
ក្បែលក្នុងជលរីករាយ ព្រលិតលេចលាយ ទីងដើមស្អូនស្អុះ ៗ សត្បុល
ទីលុប្បលជាសផុះ ឈូកឈរច្រើនច្រុះ ប្រាសប្រាលសឹងផ្កា ៗ ត្រកៀត
សឹកសៀតស្លាបទា ស្មោមស្លាបប្រា កំពង់តួយពន្ធ ៗ ស្លូងសាយសា-
ពយដើងមានទ់ ក្របាប់ណែនណាន់ ត្រកួនកញ្ឆែត ៗ មច្ឆារេក
អណ្តែត ហក់ហែបហែលហាត់ រេកបរគោក្កា ៗ អ្នកស្រង់កម្សងគង្គា
ជម្រះកាយា ស្រេចបរិបូណ៌បាន ៗ ឡើងពីស្រះស្រីក្សេមក្សាន្ត ដល់
ផ្ទះមើលមាន សុទ្ធសឹងដើមផ្កា ៗ មហាហង្សត្រយងយុក្កា ខ្ទឹងខ្ទំ
បម្លា បម្លីបេកទេស ៗ មុន្ត្រីលន្លែការកេស នូវនួនពិសេស ម្ទិះវត

ម្ទ័ះលា ។ ឈូករត្នព្រលិតក្តាំងផា រម្តេញមាសប្បារ រំបេកមាលដី ។ រំចាកបោសនាគខ្ទួនស្រី ចន្ទសូរភី ស្បៃរឿងរំដួល ។ ដាំដុះច្រើន ប្រុះដាជួរ រៀងពល់គាប់គួរ ដោយឆ្នេរស្រះស្រង់ ។ អ្នកខានសម្រាន្ត ផ្ទុំក្នុង ព្រៃប្របកម្ពង់ ឆ្នៀឆ្នេរស្រះស្រី ។ លុះស្រាងព្រឹកព្រាងរង្សី ឯកក្សត្រធិបតី សត្តកូដរាជា ។ ព្រះអង្គស្តេចទ្រង់ចិន្តា បង្គាប់ទៅថា នឹង មេទាសី ។ ឲ្យយកក្អមមកបានបី ទៅដងទឹកពី ស្រះស្រង់រង្ថា ។ មកស្រង់នៃអង្គធីតា ដម្រេះកាយា ផ្សះព្រះកេសី ។ ស្រីង្គាបរិពារនារី លុះព្វាក្យពី ស្តេចទ្រង់បង្គាប់ ។ ម្នីម្នាហៅគ្នាប្រញាប់ កាន់ក្អមផ្កាប់ ទូលទុកសិរសា ។ ផ្អៀងផ្អងត្រសងនាំគ្នា ទាំងបីយាត្រា ដើរដល់ស្រះ ស្រង់ ។ ផ្កាសំពណ៌បុះបរទៅក្នុង ជលសាថ្វាយង់ ដងដាក់ក្អមពេញ ។ នាំគ្នាលីលាវិលវិញ យួរយកក្អមមិញ ដាក់ដល់ឆ្នេរស្រះ ។ ស្រេច ស្រូតទៅផ្ទូតដម្រេះ មន្ទិលអង្គះ ក្នុងជលសាសាន្ត ។

**បទកាកគតិ**

កាលណោះព្រះពោធិសត្វសេដ្ឋា អ្នកនៅសម្រាន្ត ឈប់ខាន ឆ្នេរស្រះ ប្រទះយល់ប្រាណ ស្រីទាំងពាបាន មកដងគង្គា ។ ទើបអ្នក គន់គិត អធិស្ឋានចិត្ត តាំងផ្សងឡើងថា ខុអស់ទេព្រក្ស អារក្ខទេវតា ចិតឋានសួគ៌ា ភពភូមិដែនដី ។ តេជះខ្ញុំរក សូមអ្នកចូលមក ជួយ ជាសាក្សី បើនាងសុខុមា-លន្ធាទេវី នឹងបានមេត្រី ជាគូផងគ្នា ។

សូមឲ្យក្អមនោះ ធ្ងន់ក្រៃបំពោះ ដូចថ្មសិលា កុំឲ្យអស់ស្រី ទាំង៣ នេះណា លើកក្អមគន្ធា ដល់សិរសាបាន ៗ ផ្សងស្រេចពុំលង់ ក្សណា នោះអស់អគ្គ ស្រីទាំង ៣ ប្រាណ ងូតទឹកស្រេចស្រាប់ ក្រឡាប់រិល ប្កាន ដល់ឆ្នេរជលសាទ ហើយផ្លាស់ពស្ត្រា ៗ ដាក់ដៃថ្នាក់ថ្នម យូរ យកទឹកក្អម ធ្ងន់ក្រៃមហិមា ពិតពុំកើត ប្រួតលើកជួយគ្នា ក្អមទឹកនោះ ពា នៅទីងដូចគល់ ៗ លុះលាន់មាត់ថា ពុំឆ្ងាលា ៗ គិតគួរតែឆ្ងល់ ក្អមអ្វីនេះប្លែក បំឡែកពេកសល់ អញពុំដែលយល់ ដែលឃើញដូច្នេះ ៗ មេមួយធាត់ធំ ពាលពេញក្រមុំ ដេរថាមេនេះ ហាងឯងដៀសចេញ ឲ្យអញឯងអេះ ធ្ងន់អ្វីប៉ុណ្ណេះ អញលើកដាក់ឲ្យ ៗ ដាំតែបុះបាយ ដណ្តើមប្រញាយ ដែលក្រយាស្ងោយ សេសសល់ចំណី បានធី បែរក្រោយ កម្ចាំងកំសោយ ដូចគេអត់បាយ ៗ ដេរហើយប្រឹងលើក ពិតពុំកើត បែកញើសហូរខ្លាយ ហត់ហើយស្រងី ធ្ងន់អ្វីអម្បាយ អញគិតមើលឆាយ ស្មានណាស្រាលទេ ៗ មេនោះឆ្លើយវិញ ថា ហាងដេរអញ អ្នួតឯងពូកែ កន្ទ្រលតតបទ មានមាត់ស្រួចតែ រំលើក ដេរគេ តាមតែនឹងថា ៗ កាលណោះពោធិ៍ យល់មេទាំងបី លើក ក្អមគន្ធា ពុំរួចដាក់ដល់ មណ្ឌលសិរសា ទើបអ្នកយាត្រា ចេញ ចរទៀបទៅ ៗ អស់ស្រីផងយល់ មានចិត្តអរសល់ ហោយដៃហើយ ហៅ អង្វរចរចា ·លោមបាហៃទៅ កំឡោះល្អញល្អៅ មានរូប

សោកា ៗ សូមអ្នកប្រោសព្រាយ អាស្សូមកជួយ លើកក្អមគង្គា ដោយដាក់ដំកល់ មណ្ឌសិរសា កុំអ្នករួញរា ធុញថានាយអាយ ៗ ព្រះពោធិសត្វ មហាបុរសរត្ន លើសលោកទាំងឡាយ សាកសួរទៅ វៃ ថាហៃនាងអាយ លំនាំដោមឆាយ ហាក់ស្រីអ្នកលើ ៗ មកដងទឹកឯង ឬគេតាក់តែង បង្គាប់ប្រាប់ប្រើ មកដងទឹកនោះ ចំពោះបានបើ ធ្វើតធីកប្តីឱ្យ អ្វីប៉ុប្រាយប្រាប់ ៗ សារដៃទាំងបី ពាក្យពោធិ- សត្វ សួរសារសត្វ ទើបមេមួយឆ្លើយ អ្នកអើយអ្នកស្តាប់ ខ្ញុំនឹងប្រាយប្រាប់ ឱ្យអ្នកដឹងជាន ៗ ដ្បិតកំដបុត្រី ក្សត្រាធិបតី តស្សូរថ្កើងថ្កាន ព្រះតន្ទ ថមថៅ យកទៅឱ្យមាន ប្តីនៅពារា-ណសីនគរ ៗ នាងនៅពុំសុខ អំពល់ជាទុក្ខ ទើបនាងចាកចរ រិលរីងឆ្ពោះមក រូសរកព្រះវរ- បិតាក្ស- ត្រ ទូរព្រះមាតា ៗ ទើបក្សត្រទុក្ខ ត្រាស់ប្រើយើងខ្ញុំ មកដងគង្គា យកទៅជម្រះ ផ្សះព្រះកេសា នៃនាងនាថជា បុត្រីកល្យាណ ៗ ពោធិសត្វស្តាប់ សារដៃប្រាយប្រាប់ ដឹងដើមពត៌មាន ថានាងមកដល់ មណ្ឌលពជឋាន ពើសព្រះទ័យក្សាន្ត សោមនស្សាសល់ ៗ អ្នក យកព្រះទ-ម្រង់មកដាក់គង ក្អមមាសនិមិល មិនឱ្យអស់ស្រី ទាសីឯងយល់ ទៀងទើបទសពល អធិដ្ឋានថា ៗ បើនាងស្រប់ស្រង់ ជម្រះ អស់អ-ង្គាកាយធីតា សូមឱ្យទម្រង់ បញ្ជាំងថ្ងៃថ្លា ប៉ូលម្រាមហត្ថា ដូចគេបំពាក់ ៗ តាំងចិត្តសច្ចា ឆ្ងង់ស្រេចព្រះមហា-បុរសចមចក្រ យ៉ា

យកទឹកក្អម ថ្នាក់ថ្នមហើយអ្នក សូមស្ងួយដល់ដាក់ លើក្បាលទាសី ។
សាវ៉ៃត្រេកអរ អំពើចិប្ចប់ លាព្រះពោធិ៍ ទូលទឹកក្អមទៅ លំនៅ
ទិព្វទី នៃនាងនារី ដល់ស្រេចច្បាស់ថ្វាយ ។ ទើបកាងធីតា ស្រប់ស្រង់
គង្គា ជម្រះព្រះកាយ ផ្សះព្រះកេសា ហត្ថាពណ្ណរាយ ប្រោយប្រង
សិរសាយ កេសីរល័ក្ខណ៍ ។ សាវ៉ៃស្ងួយក្អម មាសម៉ៃថ្នាក់ថ្នម
លើកទៀងផ្អៀងចាក់ ទឹកទាំងព្រះទម្រង់ នៅក្នុងក្អមធ្លាក់ ដូចគេបំ-
ពាក់ ព្រះហស្តក្សត្រិយ៍ ។ នាងទតយល់ជាក់ ដឹងដើមរៀមរ័ក
ជាព្រះស្វាមី តាមមកដួបដល់ មណ្ឌលស្រះស្រី នាងនាដនារី
ត្រេកសោមនស្សា ។ អរឯងពេកពន់ នាងត្រាស់សួរដ- ណ្តឹងសាវ៉ៃថា
ហង់ទៅដងទឹក ពីព្រឹកសុរិយា ទៅលេងឯណា បាត់យូរអម្បាយ ។
ហើយហង់ឯងបាន បំពៀនមាសមាន ត្បូងរត្នពណ្ណរាយ ដាក់ក្នុង
ទឹកក្អម លើកថ្នមមកថ្វាយ ចូរហង់និយាយ បានពីនរណា ។
សាវ៉ៃបង្គំ ទូលថាកាលខ្ញុំ ទៅដងគង្គា អំពីកំពង់ ស្រះស្រង់ផលសា
មានហេតុយល់ជា អស្ចារ្យពេកពន់ ។ បានជាបាត់យូរ សូមម្ចាស់អា-
សូរ ឲ្យគង់ពីពជន្ម ក្អមទឹកស្រាលទេ ម្តេចប្រែជាធ្ងន់ ធ្ងន់ក្រៃពេកពន់
ខ្ញុំមិនដែលយល់ ។ ព្រួតគ្នាជួយលើក មិនមានកម្រើក នៅទឹងដូចគល់
កោយរសាយដៃ គាប់ចៃបានយល់ ប្រុសមួយនិម៉ិល កំឡោះសោភា ។
ដើរមកប្រទះ យើងខ្ញុំសំពះ អង្វរគ្រប់គ្នា គាត់មកជួយថ្នម លើកក្អម

គង្គា ដាក់ដល់សិរសា ខ្ញុំទាំងបីនាក់ ៗ ទើបខ្ញុំទូលយក ក្អមទឹក នោះមក ថ្វាយម្ចាស់ទ្រង់លក្ខណ៍ ចិញ្ចៀននេះឯង ខ្ញុំក្រែងតែអ្នក ប្រុសនោះលបដាក់ មកក្នុងគង្គា ៗ នាងស្តាប់សំដី ពាក្យពីតាសី នាងប្រាបជាក់ជា ព្រះស្វាមីមក តាមរកធីតា ត្រេកសោមនស្ស អរឥតប្ចឹងថ្លែង ៗ ព្រះឧស្សទិព្វគន់ ត្រាស់ទ្រង់បំអន់ ថាអស់ហ្មងឯង ពីពាក្យមាយា មុសាឥតក្រែង នាំគ្នាដើរលេង ទៅរកសហាយ ៗ ចួបចូនប្រុសប្រាណ ប្រែឡែងគ្នាបាន កៀកកនិយាយ អស់ចិត្តទើប យក ទឹកមកថ្វាត់ថ្វាយ កក្កូតប្រាប់ប្រាយ ថាក្អមទឹកជូន ៗ សាវដៃ កាំងកិត ទូលថាបពិត្រ ម្ចាស់ថ្លៃមានបុណ្យ ខ្ញុំទូលពំនិត្យ ពាក្យពិត ពេកពន់ ពិតជាក្អមជូន ពុំហានមុសា ៗ នាងនាចកក់ស្រង់ ស្រេច ក្សត្រីទ្រង់ គ្រឿងពណ៌ពស្ត្រា គាក់តែងព្រះអង្គ ហើយនាងលីលា ឡើងគាល់បិតា ធិពដច្ចើងចូល ៗ ដល់ស្រេចនាងថ្វាយ បុស្បក្ក័ដកាយ ករកបកោមល ទូលថាដ្បិតប្តី ស្វាមីនិម៌ល តាមខ្ញុំមកដល់ ស្រះ ស្រង់ជៀងដាក់ ៗ ដ៏ងដោយតាសី ទៅដងទឹកពី ស្រះចួបនឹងអ្នក យកព្រះទម្រង់ រត្នផ្ទង់ទំលាក់ ក្នុងក្អមដែលដាក់ ទឹកទូលឡើងមក ខ្ញុំងូតគង្គា ទើបយកហត្ថា ជែងជ្រួយសក់សឹក ចិញ្ចៀនទម្រង់ ដោយក្នុងទឹកមក ដូចគេពាក់ប្រែក នៅម្រាមកូនដៃ ៗ (**មាតក**)

មុនីភាសិត

# មហា "ឱម-ណាគ្រី"

ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង ប្រែរៀបរៀង,

## ធម្ម រតនត្តយស្ស

ខ្ញុំនាមដើម "ឱម - ណាគ្រី" ទីបណ្ឌិត
សូមប្រណីតប្រណម្យកាយថ្វាយបង្គំ
ព្រះជិនិន្ទពិន្ទុសម្ពុទ្ធវរុត្តម,
ព្រះសទ្ធម្ម, ក្រុមព្រះសង្ឃអគ្គសាវក ៗ
រួបសូមប្រែកែសំដែងវែងភាសិត
ទុកជាក្រមផ្សំជាក្រិត្យមានសារៈ
បែកបំណាយផ្សាយជំនូនជូនលោកអ្នក
ពុទ្ធិកៈសប្បុរសទាំងប្រុសស្រី ៗ
ខ្ញុំដកស្រង់ពីក្បួនច្បាប់ច្រើនអន្លើ
យកមកធ្វើជាកាព្យឃ្លោងឃោងសេចក្តី
ទុកជាបទកត់ជាបែបសង្ខិបខ្លី
ឲ្យឈ្មោះថ្មីថា "មុនីសុភាសិត" ៗ
សូមសាសនាព្រះគោតមចមគ្រូយើង
បានរុងរឿងថ្កើងរុងរោចន៍ទីងថេរបិត .

សូមស្រុកខ្មែរបែរទៅរកវឌ្ឍនៈវុឌ្ឍិ
អបរាជិតសិទ្ធិជោគចូរកើតមាន !!! ។

# ពុទ្ធគុណវគ្គ

ឱភាសិ វិសាខា យា  តាយ យុត្តាវ ចន្ទិមា
បុណ្ណា តេន ច យុត្តា  យា វិសាខបុណ្ណមី តិថី ។

តិថីឯណាថ្ងៃថាសោភ័ណ  ភ្លឺដោយដួងចន្ទពេញវង់សោភា
ត្រចះត្រចង់រុងរឿងនៅនា  អាកាសវេហាសៈនភាល័យ ។
គោចរជុំវិញផ្កាយឫក្សល្អផាក់  ឈ្មោះវិសាខៈសោភៈពេកក្រៃ
តិថីនោះឈ្មោះ "វិសាខបុណ្ណមី"  ចន្ទពេញស្មើនៃខែពិសាខ ។

ជិត្វា អភិសម្ពុទ្ធោ  តស្សំយេវ ច និព្វុតោ
លោកស្ស ទេសិតោ សត្ថា អមតំ បទមេសតោ ។

ព្រះសម្ពុទ្ធបរមសាស្តា  ជាដួងនេត្រានៃលោកពិភព
ព្រះអង្គប្រកាសត្រាស់ពន្យល់ប្រាប់  នូវធម៌មិនស្លាប់ឈ្មោះអមតៈ ។
ទ្រង់បានប្រសូតចាកគភ៌មាតា,  ត្រាស់ដឹងធម៌កាត់ចិត្តទើសបំពាក់,
និងចូលនិព្វានកាន់ស្ថានសិវៈ,  ក្នុងតិថីលក្ខណ៍នោះទាំង ៣ គ្រា ។

សិលោកមនុកស្សាមិ  តស្ស វណ្ណប្បកាសកំ
អព្ភញ្ញាយ រូបេន  បសាទេន តថាគតេ

ដោយបញ្ញាការរេះដឹងតិចពិត តែដោយរីកចិត្តជ្រះថ្លាពេញទី
ក្នុងព្រះតថាគតបរមមុនី ខ្ញុំសូមវទីពោលស្លោកប្រកាស ។
អំពីព្រះគុណអនន្តអនេក អនគ្ឃពន់ពេកនៃព្រះពុទ្ធម្ចាស់
ដោយពាក្យនិពន្ធតាមគន្ធសាស្ត្រ លោកបានប្រកាសទុកពីបុរាណ ។

ពុទ្ធោបិ ពុទ្ធស្ស ភណេយ្យ វណ្ណំ
កប្បម្បិ ចេ អញ្ញភាសមានោ
ខីយេថ កប្បោ ចិរទីឃមន្តរេ
វណ្ណោ ន ខីយេថ តថាគតស្ស ។

សូម្បីព្រះពុទ្ធម្ចកពត្រ័យ គប្បីពោលគុណព្រះពុទ្ធផងគ្នា
អស់កប្បវែងឆ្ងាយអន្ទាយយូរយារ មិនពណ៌នាធម៌អាចិដវៃ ។
កប្បដ៏យូរលង់រព់ងបន្ទោះ ក៏ទឹងផុតអស់កន្លងសម័យ
ឯគុណព្រះពុទ្ធវិសុទ្ធិវិស័យ មិនហោចហ៊ានវៃអស់ទៅផងឡើយ ។

សហស្សសីសេ បិ ចេ ចោសោ
សីសេ សីសេ សតំ មុខា
មុខេ មុខេ សតំ ជិវ្ហា
ជីវកប្បោ មហិទ្ធិកោ
ន សក្កោតិ ច វណ្ណេតុំ
និស្សេសំ សត្ថុនោ គុណំ ។

បុរសម្នាក់មានក្បាលសហស្ស ក្បាលមួយៗ នោះមានមាត់មួយរយ
មាត់មួយៗ មានអណ្ដាតជាប់ដោយ មួយរយៗ គ្រប់មាត់នោះឯង ៗ
បុរសនោះមានអាយុមួយកប្ប មានបុទ្ធិស្វាហាប់, ក៏មិនអាចថ្លែង
ពណ៌នាព្រះគុណព្រះសាស្ដាស្ដែង ឲ្យអស់រលីងមិនសល់បានឡើយ ៗ

ចត្តារោ លោកេ បជ្ជោតា បញ្ចមេត្ថ ន វិជ្ជតិ
ទិវា តបតិ អាទិច្ចោ រត្តិមាភាតិ ចន្ទិមា
អថ អគ្គិ ទិវា រត្តឹ តត្ថ តត្ថ បកាសតិ
សម្ពុទ្ធោ តបតំ សេដ្ឋោ ឯសា អាភា អនុត្តរា ៗ

ពន្លឺក្នុងលោកមានតែ ៤ គត់ មិនមានកំណត់ដល់ ៥ ប្រការ
ព្រះអាទិត្យបំភ្លឺក្នុងទិវា ឯព្រះចន្ទ្រាភ្លឺទារាត្រី ៗ
ភ្លើងបំភ្លឺសព្វក្នុងទីនោះៗ ធ្លុះភ្លឺទាំងយប់គ្រប់ទាំងពេលថ្ងៃ
បំណែកព្រះពុទ្ធមួដកពាត្រៃ ប្រសើរលែងក្រៃពន្លឺទាំងអស់ ៗ
ពន្លឺគឺព្រះសម្ពុទ្ធម្ចាស់នេះ រុងរឿងវិសេសវិសាលខ្ពង់ខ្ពស់
លើសលុបលើសលែងពន្លឺទាំងអស់ ពន្លឺនោះៗប្រៀបពុំបានឡើយ ៗ

វធកេ ទេវទត្តម្ហិ ចោរេ អង្គុលិមាលកេ
ធនបាលេ រាហុលេ ច សព្វត្ថ សមមានសោ ៗ

ព្រះពុទ្ធបរមពង្សវង្សដ៏មានគោត្រ ខ្ពស់លើសត្រៃលោកជាម្ចាស់អង្គនោះ
ទ្រង់មានព្រះហឫទ័យស្ម័គ្រស្មោះ ស្មើៗចំពោះក្នុងពពួកសត្វ ៗ

គឺកង្វល់ពួកក្រុមនាយខ្មាន់ជ្ឋ   កង្វល់លោកគ្រូឈ្មោះព្រះទេវទត្ត
កង្វល់មហាចោរដែលសន្ធត   ឈ្មោះគាត់ហៅថា អង្គុលិមាល ។
កង្វល់ព្រះឱរសនាមរាហុល:   ជាព្រះរាជបុត្រដ៏វិសាល
និងកង្វល់ដំរីឈ្មោះធនបាល   ដ៏សព្វៗ កាលគត់មានរើសមុខ ។

ពព្ហុំ រត អគ្គាយ   មាយា ជនយំ គោតមំ
ព្យាធិំ មរណតុណ្ហាំ   ទុក្ខក្ខន្ធំ ព្យាធានុធំ ។

ព្រះនាងសិរិមហាមាយា   ប្រសូតបុត្រានាមព្រះគោតម
ដើម្បីប្រយោជន៍សុខសាន្តដ៏ធំ   ដល់ក្រុមនិករសត្វក្នុងត្រៃវដ្ត ។
ព្រះអង្គទ្រង់បន្ទោទុក្ខទោមនស្ស   របស់សព្វសត្វឲ្យបាត់ស្ងប់ស្ងាត់
ដែលព្យាធិមរណៈគ្របសង្កត់   ឲ្យបានរលត់រលាយមិនសល់ ។

ពោធនេយ្យំ បជំ ទិស្វា សតសហស្សំ យោជនំ
ខណេន ឧបគន្ត្វាន   ពោធេតិ តំ មហាមុនិ ។

ព្រះមហាមុនីមុនិន្ទបមពង្ស   ទ្រង់ឃើញជនណាដែលមាននិស្ស័យ
គួរត្រាស់ដឹងធម្មាភិសម័យ   សម្បីផ្លូវឆ្ងាយរាំងសែនយោជន៍ណា ។
ក៏ស្តេចយាងទៅដល់ដោយរហ័ស   ហើយទ្រង់ប្រកាសសំដែងធម៌អាថ៌
ញុំាងជននោះៗឲ្យកើតជ្រះថ្លា   ឲ្យបានដល់ការត្រាស់ដឹងធម៌ថ្លៃ ។

លោកោ ទុក្ខេន សន្តត្តោ តណ្ហា ទុក្ខស្ស សម្ភវា
តណ្ហាយាតេន ទុក្ខគ្គំ   ញុត្តោ ទេសេតិ ធានធំ

សត្វលោករឹតរុំដោយសេចក្ដីទុក្ខ   តណ្ហាប្រមុខនាំកើតទុក្ខភ័យ
នឹងផុតចាកទុក្ខសោកទោសចង្រៃ   បានព្រោះអាស្រ័យសម្លាប់តណ្ហា ។
ព្រះពុទ្ធជាម្ចាស់ទើបប្រកាសប្រាប់   នូវគន្លងច្បាប់សម្លាប់ "ប្រាថ្នា"
ដែលឲ្យរលត់ផុតចាកទុក្ខា   សម្រាប់ទេពតាមនុស្សសត្វទូទៅ ។

កាយកំ ចាតុសីលេន   អថោ ចិត្តំ សមាធិនា
ទិដ្ឋឹ បញ្ញាយ សោធេត្វា   រក្ខាបេតិ មហាមុនិ ។

ព្រះមហាមុនិន្ទពិនូវឧត្តម   តែងនាំក្រុមសត្វនិករទាំងឡាយ
ឲ្យថែរក្សាពានឹងកាយ   ដោយសីលនោមឆាយដ៏ស្អាតផូរផង់ ។
ឲ្យឃុំគ្រងចិត្តគំនិតនឹងនួន   ដោយក្បួនសមាធិធម៌ឧត្តុង្គ
ឲ្យពត់ទិដ្ឋិការយល់ត្រូវត្រង់   ដោយអង្គបញ្ញាពិចារណ៍ពិនិត្យ ។

យាវ អជ្ជត្តនា ករុណា   សចេ លោកម្ហិ បស្សតិ
សន្តោ លោកោ ករុសន្តោវ   អហោនាថ សនិព្វុតោ ។

ព្រះបរមសាស្តាអាទិច្ចវង្ស   បើព្រះអង្គទ្រង់គង់ព្រះជន្មនៅ
គង់លោករហូតសព្វថ្ងៃឥឡូវ   សត្វលោកទូទៅនឹងស្ងប់សែនស្ងប់ ។
តែអនិច្ចា ! ឥឡូវទ្រង់ញាណ   យាងចូលនិព្វានចាកលោកពិភព
ជាយូរយារហើយខ្ញុំសូមគោរព !   ខ្ញុំសូមគោរព ! អំពីចម្ងាយ ។

ធម្មោ វិនយោ តស្ស   សត្ថា នោ វត្តតិ
តស្មា សោ និព្វុតោ កាមំ   សាសនំ បន តិដ្ឋតិ

ធម៌និងវិន័យរបស់ព្រះអង្គ ទៅគង់ជំនួសជួសជាសាស្តា
នៃយើងទាំងឡាយទាំងមនុស្សទេព្តា ឲ្យខំសិក្សារៀនសូត្រគារវៈ ។
ព្រោះហេតុដូច្នោះ សូម្បីព្រះអង្គ និព្វានយូរលង់ក៏មែនពិតជាក់
តែពាក្យប្រដៅពុទ្ធវចនៈ ជាវរៈគង់វង់ឋិតថេរនៅឡើយ ។

**កោ នុ ថោមយតី សត្ថា បដិបត្តិមនុត្តរំ**
**យោ សទ្ធោ ស ចរេ ធម្មំ យតោ្វ គោវលវទ្ធនំ ។**

ឪព្រះសាស្តាម្ចាស់អង្គណាហ្ន៎ ! ដែលទ្រង់សរសើរដំណើរចរិយា
កិច្ចប្រតិបត្តិប្រពៃថ្លៃថ្លា ថាប្រសើរជាងបូជាអាមិស ។
នរណាមានចិត្តជំនឿជឿពិត ក៏ចូរប្រព្រឹត្តតាមក្រឹត្យធម៌ចុះ
ល្អតែក្រោបៗ សំពះៗ តើបានអ្វីខ្លះ? និងធ្វើអ្វីកើត? ។

**កោ នុ សាសតិ អត្តស្ស តយំ ឥធ អសាសិយំ**
**សត្ថុំ សម្បាទនេហោវ សចេ សោ ន តថាគតោ**

ព្រះបរមសាស្តាម្ចាស់អង្គណាហ្ន៎! អាណិតអាសូរប្រដៅខ្ញុំបាន
ប្រយោជន៍ទាំងពួងដែលមិនដែលមាន នរណាខ្ញុំបានក្នុងលោកនេះសោះ ។
ព្រមទាំងខប្រតិបត្តិប្រើនហាន ដែលនាំឲ្យបានសម្បត្តិទាំងអស់
បើព្រះសាស្តាជាម្ចាស់អង្គនោះ មិនគឺចំពោះព្រះតថាគត ! ។

**ជនោ ជិវនជានទ្ធ ការពត្ថុស្ស ភាសិតំ**
**សត្ថាភោន្តោ បរេយ្យាតិ បុញ្ញាវិត្វា យតោ ចរេ ។**

ជនណាបើបានធ្វើសក្ការៈ　　បូជាគារវៈតាមទំនងពិត
ដែលព្រះសម្ពុទ្ធផៅពង្សរុងរិទ្ធិ　　ដូចពង្សអាទិត្យសំដែងទុកមក ។
ជននោះទើងបានសុខសាន្តសែនសល់　　គឺទើងបានដល់មគ្គផលផុតសោក
មានព្រះនិព្វានជាអារម្មណ៍យោគ　　កន្លងផុតលោកលែងជ្រកក្នុងភព ។

**ឯថ ភោន្តា និសាមេថ　　សម្មាសម្ពុទ្ធសាសនំ**
**គតោ ធំ បដិបជ្ជេថ　　បិវេថ អមតំ រសំ ។**

មកចុះ លោកអ្នកចំរើនទាំងឡាយ !　　អញ្ជើញខ្វល់ខ្វាយពិនិត្យពិសោធ
ពាក្យប្រៀនប្រដៅនៃព្រះសម្ពោធិ៍　　ពិនិត្យពិសោធឲ្យបានជាក់លាក់ ។
ដំណើរជាប់តអំពីនោះពិត　　អញ្ជើញប្រព្រឹត្តតាមសាសនៈ
លោកក៏នឹងបានក្រេបផឹករសៈ　　នៃអមតៈ គឺព្រះនិព្វាន ។

**ឥមាយ ការិកាយ　　មយា សង្ខំ សុភាសិតំ**
**ចិរំ តិដ្ឋតុ សទ្ធម្មោ　　បជាយ អនុកម្បិតុំ ។**

សព្វៈពចាដែលខ្ញុំម្ចាស់　　បានពោលប្រកាសយ៉ាងល្អប្រពៃ
ដោយឆន្ទៈសាស្ត្រសំនួនករ៍　　ទាំងខ្មែរបាលីទាំងអស់នេះណា ។
សូមព្រះសទ្ធម្មបូរទ្រាំបេរបិត　　គង់វង់នៅនិត្យអស់កាលយូរយា
ដើម្បីអនុគ្រោះចំពោះប្រជា -　　ជនជាតិនានាក្នុងលោកនេះហោង ៗ

(មានត)

ចប់ពុទ្ធគុណវគ្គ

# ពន្លឺអាស៊ីទ្វីប

## ព្រះនិពន្ធមន្ត្រី ញ៉ុក - ថែម

ប្រែ - រៀបរៀង

(តមក)

---

នេះជាទំនាយរឿងបញ្ហានោះ, ឯមនុស្សទាំង ៦ នាក់ដែលយំសោកត្អូញថ្ងូរបិទមាត់ គឺសាស្ដាចារ្យសំខាន់ទាំង ៦ នាក់ដែលព្រះរាជឱរសទឹងទ្រង់ធ្វើឲ្យបាត់ដឹងខ្លួន ក្នុងអាការធ្វេសធ្វាសរបស់ខ្លួន ដោយព្រះបារមីដ៏ទៀងត្រង់ នឹងព្រះធម្មទេសនាដែលមិនមានរឿងជជែកបាន, ឱ ! ព្រះរាជាសូមទ្រង់ក្រេមក្សាន្តសម្រាន្តព្រះទ័យចុះ ព្រះករុណាសម្បត្តិរបស់ព្រះរាជឱរសមានដំលៃលើសលែងរាជអាណាចក្រទាំងមូល, សំពត់ ( ស្បង់ចីពរ ) ដាច់រយ៉ីរយ៉ៃមានដំលៃក្រៃលែងសំពត់ដែលគេត្បាញដោយខ្សែមាស; ព្រះសុបិននិមិត្តរបស់ព្រះអង្គ ប្រែបានសេចក្ដីត្រឹមប៉ុណ្ណោះឯង ហើយខាងក្នុង ៧ ទិវា ៧ រាត្រី, របស់ទាំងពួងនឹងប្រព្រឹត្តបង្កើតឡើង" កាលបុរសអស្ចារ្យនិយាយចប់ហើយក៏ក្រាបចុះយ៉ាងទាប ៨ ដង ប៉ះពាល់ដល់ដី ៣ ដង ត្រឡប់ប្រែខ្លួនហើយថយចេញទៅ តែកាលដែលព្រះរាជាទ្រង់ទតឲ្យរកខ្លួនមកនឹងព្រះរាជទានរង្វាន់មានដំលៃ, អាមាត្យដែលទទួលព្រះរាជឱង្ការត្រឡប់មកទូលថា "ទូលព្រះបង្គំតាមទៅរហូតដល់ព្រះវិហារចន្ទ្រា ដែលឃើញគាត់ដើរចូលទៅ តែកាលចូល

ទៅដល់កន្លែងនោះ   ក៏ស្រាប់តែឃើញទំនុយសំបុរប្រផេះ ១ ហើរចេញពីបន្ទន់ទៅ" ។ (មានប្អូនកាលទេព្តាដំណែងមកឲ្យឃើញដូច្នេះដែរ) ។

ព្រះរាជាដែលទ្រង់ត្រៀមក្រកន្លព្រះទ័យ   កាលទ្រង់ព្រះសណ្ដាប់ពាក្យទំនាយសុបិននោះហើយ   ទ្រង់ស្លុតព្រះហឫទ័យ,   ទ្រង់ចាត់ចែងប្រលោមព្រះសិទ្ធត្ថដោយវិធីធ្វើឲ្យក្រេមក្សាន្តឡើងថ្មី   ក្រៅអំពីនេះ   ទ្រង់បន្ថែមកងរក្សាព្រះទ្វារឲ្យម៉ឺងម៉ាត់ឡើងទៀត   ។

ចុះនរណា អាច ហាមឃាត់មិនឲ្យប្រព្រឹត្តទៅតាមផ្លោតជតាក់ស្មារបស់ខ្លួនបាន !

តាមដោយពិត   ព្រះរាជបុត្រមានព្រះបំណងប៉ងចេញទៅទតព្រះនេត្រហ្វូងប្រជាជនដ៏ងងំដណើរនៃជីវិតមនុស្សទៀត   ដែលជារបស់គួរឲ្យពិតពិលរមិលមើល   ប្រសិនបើដំណើររបស់មនុស្សទាំងនោះ   មិនបានទៅកាន់សេចក្ដីវិបាកគឺមរណៈ ដែលជាបំផុតនៃកាលវេលា   ទើបព្រះរាជ-នរសក្រាបទូលព្រះបាទសុទ្ធោទនៈថា   "សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោសអនុញ្ញាត   ឲ្យទូលព្រះបង្គំចេញទៅមើលរាជធានីរបស់យើងតាមសភាពធម្មតា,   កាលគ្រាមុននោះ,   ដោយអំណាចព្រះមហាករុណា-ធិគុណរបស់ព្រះអង្គ   ទើបព្រះអង្គទ្រង់ហាមមិនឲ្យសត្វលោកដែលទល់ទុក្ខវេទនា   នឹងមិនឲ្យមានសភាពធម្មតាប្រាកដ   មានតែទ្រង់ឲ្យមនុស្សគ្រប់រូបនឹងសភាពធម្មតាគ្រប់យ៉ាង   ប្រកបដោយសេចក្ដីក្រេមក្សាន្តរីករាយ

ដើម្បីផាត់សុខសម្រាន្តនៃទូលព្រះបង្គំ ព្រមទាំងធុរវល់គ្រប់អន្លើក៏ឲ្យ
មានតែការរីករាយក្សេមក្សាន្ត ទោះបីដូច្នោះ ទូលបង្គំក៏បានដឹងច្បាស់ថា
របស់ទាំងឡាយ មិនមែនប្រព្រឹត្តទៅតាមធម្មតាដែលមាននៅសព្វថ្ងៃទេ,
ដោយហេតុទូលព្រះបង្គំជាអ្នកនៅជិតព្រះអង្គ នឹងព្រះរាជាណាចក្រ
ក្រៃលែងជាងអ្នកឯទៀតៗ, ទូលព្រះបង្គំបានស្គាល់ការណ៍ប្រជាជននឹង
ធុរវល់ទាំងឡាយ តាមសភាពធម្មតានៃរបស់អស់នោះ, កិច្ចការធម្មតា
សព្វៗថ្ងៃ នឹងការចិញ្ចឹមជីវិតរបស់ប្រជាជនដែលមិនមែនព្រះរាជា,
បពិត្រព្រះអង្គដ៏ទ្រទ្រង់ព្រះគុណធម៌ដ៏ប្រសើរ, សូមទ្រង់អនុញ្ញាតឲ្យ
ទូលព្រះបង្គំចេញចាកព្រះរាជឧទ្យានដ៏សុខសម្រាន្តរបស់ទូលព្រះបង្គំទៅ
ដោយស្ងាត់ៗ ទូលព្រះបង្គំនឹងត្រឡប់បានមកវិញដោយបីតិរីករាយពុំខាន
ឬមិនរីករាយទេ ក៏គង់បានសេចក្តីចេះដឹងមកកាន់ខ្លួនជាពុំខាន សូមទ្រង់
ព្រះមេត្តាបណ្តោយឲ្យទូលបង្គំចេញទៅកាន់ធុរវល់នានា នៅវេលាព្រឹក
ស្អែកនេះ ជាមួយនឹងពលបម្រើម្នាក់ប៉ុណ្ណោះចុះ ។ កាលព្រះរាជឱរស
ក្រាបបង្គំទូលដូច្នោះព្រះរាជាទ្រង់ត្រាស់ក្នុងកណ្តាលសេនាមុខមន្ត្រីរបស់
ព្រះអង្គថា "ជួនកាលការចេញដំណើរទៅលើកនេះ អាចកែដោះគំនិត
កាលចេញទៅលើកមុននេះបានខ្លះ, ឃើញទេ នេះគឺសត្វខ្លែងដែលជាប់
ចិត្តគំនិតនឹងរបស់ទាំងឡាយដែលខ្លួនបានឃើញខាងក្រោយ ដែលបាន
ផុងវង្វេងក្នុងស្នេហា, ចូរបណ្តោយឲ្យកូនយើងបានឃើញបានយល់គ្រប់

យ៉ាងទៅចុះ, ហើយចូរនាំពត៌មាននៃលក្ខណៈអាការគំនិតរបស់គេមកបញ្ជាក់ដល់យើងផង ។

ហេតុដូច្នោះ ដល់ព្រឹកឡើង, វេលាថ្ងៃត្រង់ព្រះរាជបុត្រនឹងនាយឆន្នកក៏ចេញពីព្រះទ្វារ ដោយអ្នកយាមបានឃើញព្រះរាជលញ្ឆករ ក៏បើកព្រះទ្វារឲ្យចេញទៅដោយស្រួល តែអ្នកបើកទ្វារមិនបានស្គាល់ថា អ្នកដែលតែងកាយជានាយពាណិជចេញពីទ្វារទៅនោះជា ព្រះរាជបុត្រទេ ទាំងនាយសារថីសោតទៀតក៏តែងខ្លួនជាមនុស្សសាមញ្ញធម្មតាដែរ, ព្រះអង្គម្ចាស់នឹងនាយសារថីទាំងពីរនាក់ចេញដើរទៅតាមផ្លូវ ប្របូកប្របល់នឹងហ្វូងប្រជាជនទាំងពួង ទង់ទតព្រះនេត្ររបស់នឹងអាការដែលសុខនឹងទុក្ខទាំងពួងក្នុងព្រះនគរ បណ្តាផ្លូវថ្នល់ដ៏ល្អប្រពៃទាំងពួង ក៏បានឮតែស័ព្ទសំនៀងសៀងរវែករវោក របស់ប្រជាជនដែលធ្វើការចិញ្ចឹមជីវិតជានិច្ចនិរន្តរ៍, ពួកឈ្មួញអង្គុយបោងហោងនៅកណ្តាលគ្រឿងទេសនឹងគ្រប់កន្លែងផ្សេងៗ, ពួកអ្នកទិញក៏មានប្រាក់កាសនៅក្នុងដៃសម្រាប់ទិញអីវ៉ាន់, ខ្លះក៏ដដែកប្រកែកគ្នាក្នុងការទិញដូរ, ខ្លះក៏ស្រែកសុំផ្លូវឲ្យចេញពីកន្លែងទៅ, មានរទេះបង្គ័ដ៏ធ្ងន់អូសទាញដោយគោដ៏មានកំឡាំងទៅយឺតៗ ផ្ទុករបស់ដែលមានទម្ងន់, មានមនុស្សសែនគ្រែស្នែងស្រែកច្រៀង, ពួកកុលីដឹកញ្ជូនអីវ៉ាន់មានកដ៏មាំ ដើរទៅដោយញើសស្អុលដោយកំដៅថ្ងៃ ស្ត្រីមេផ្ទះមានក្បាលទូលផ្តាំងដី ឬផ្តាំងស្ពាន់ដាក់ទឹកដែលបានដងយកមក

អំពីអណ្តូង ហើយតាក្លូនក្អែកខ្មៅៗ នៅនិងបង្កើតផង, រានលក់ចំណី ក៏មានរុយរោមអ៊ីពាសពេញ, ជាងតម្បាញក៏ធ្វើការរបស់ខ្លួននិងត្រល់, ត្បាល់កិនក៏វិលកិនស្រូវសាលី សុនខក៏រត់ពីសពាសស្វែងរកអាហារ គោជន ជាងសាងអាវុធកំពុងធ្វើការគោះដោយដង្កាប់និងញញួរ, ជាងដែកកំពុងផុតខបនិងលំពែងឲ្យឆេះក្រហមច្រាលក្នុងឡ, នៅសាលារៀន ពួកក្មេងសាកិយៈ ដែលជាសិស្សក៏អង្គុយរៀនសូត្រ នៅជុំវិញគ្រូរបស់ខ្លួន, ខ្លះអានមន្ត ខ្លះសិក្សាតម្រាព្រះជាម្ចាស់ ពួកជាងដែលក៏នាំគ្នាជ្រលក់សំពត់ឲ្យមានសម្បុរខៀវ ពណ៌កុលាបនិងពណ៌ស្លឹកឈើ ទើបលើកស្រង់ពីចាំងជ្រលក់កំពុងនៅសើមទទឹក, ពួកទាហានកំពុងដើរលាន ឮសូរជាវនិងខែលប៉ះទង្គិចគ្នា, ពួកឃ្វាលសត្វអូដ្ឋអង្គុយយោងលើពោងសត្វអូដ្ឋ, ទ្រង់បានឃើញស្គាល់ជាក់ច្បាស់ទាំងពួកព្រាហ្មណ៍ដែលកាន់សីលធម៌, ពួកខត្តិយៈអ្នកចម្បាំងដ៏អង់អាច, ជនសាមញ្ញគឺពួកកម្មករ, នៅកន្លែងមួយនោះ មានពួកមនុស្សប្រៀតប្រៀតគ្នាទៅមើលហ្មពស់និយាយបណ្តើរយកពស់រុំដៃធ្វើជាគ្រឿងអលង្ការមានជីវិត ឬជួនកាលបង្គាប់ឲ្យអសិរពិសសាហាវនោះរាំអើតកដកពពារតាមចង្វាក់ស្គរ ដែលប្រដាប់ដោយកំទេចកែវផ្សេងៗ, ជួនកាលឃើញមានក្បួនហែនិងភ្លេងត្រែ មានសេះប្រដាប់គ្រឿងចងអានយ៉ាងរុងរឿង និងក្លស់ត្រៃ ដើម្បីហែកូនក្រមុំទៅកាន់ផ្ទះការ, ជួនកាលមានស្ត្រីបាយបួជាទំនិងកម្រងផ្កាដល់ព្រះជាម្ចាស់

បន់ស្រន់សុំឲ្យស្វាមីរបស់នាងត្រឡប់ពីការធ្វើដំណើរ ឬមិនដូច្នោះទេ បន់សុំឲ្យបានកូនប្រុស ១ ក៏មាន, ផុតឆ្ងាយពីនោះទៀត មានពួកជាងធ្វើភាជនៈខ្ទូនខ្ទៅៗ ដំទង់ដែងស្ពាន់ពាងសម្រាប់ធ្វើជាចង្កៀងនឹងឆ្នាំងបុក្គម, តពីនោះទៀត ព្រះរាជបុត្រនឹងនាយឆន្នទ្រង់យានសេះទៅតាមកំពែងវិហារ នឹងជិតទ្វារធំក៏បានទៅដល់ស្ទឹងនឹងស្ពាន ដែលនៅខាងក្រោមកំពែងព្រះរាជធានី ។

ដល់ទ្រង់យាងឆ្លងស្ពាននឹងកំពែងក្រុងផុតទៅ ដល់ទៅមាត់ផ្លូវម្ខាង ស្រាប់តែទ្រង់ឮសូរសំឡេងស្រែកយំកន្ទក់កន្ទេញថា " ម្ចាស់ថ្លៃអើយ ចូរលោកជួយខ្ញុំផង សូមលោកជួយលើកខ្ញុំផង ឱ ! ម្ចាស់ថ្លៃអើយ ជួយខ្ញុំផង ខ្ញុំមុខជាស្លាប់មុនទៅដល់ផ្ទះ !" ។ នេះជាសំឡេងមនុស្សទុគ៌តម្នាក់ កំពុងរងគ្រោះដោយជម្ងឺកាឡរោគ (ប៉េស្តិ៍) យ៉ាងសាហាវជិតនឹងស្លាប់ហើយ កំពុងបម្រះទទៀលលើផង់ធូលីដី ប្រឡាក់ដោយខ្ទុះនឹងឈាម មានដំណក់ញើសត្រជាក់ហូរចេញពីថ្ងាស, មាត់ញ័រចំប្រប់ ដោយសេចក្តីឈឺចាប់, ឯភ្នែកក្រឡិតក្រឡាប់ប្រាប់អាការគ្រល់ក្រពាយយ៉ាងខ្លាំង ។ គាត់ខំត្រដរយកដៃចាប់ស្មៅនៅផ្លូវ ដើម្បីក្រោកឡើង ហើយគ្រាន់តែងើបក្បាលឡើង ក៏ដួលស្រុសទៅវិញ ញ័រចំប្រប់សព្វសារពាង្គកាយ ហើយស្រែកគ្រលួចឡើង គួរឲ្យតក់ស្លុតថា " ហ្ន៎! ឈឺចាប់អ្វីម្ល៉េះ! លោកសប្បុរស អាណិតជួយខ្ញុំផង !" ។ (មាន)

បុណ្យបូជាសពគ្រូអាចារ្យ ហ៊ុន-ស៊ុជ

ភិក្ខុ សួន - សុន្ទ វីរិយា

(៣៦៧ - ៦៤)

---

# សេចក្ដីថ្លែងអាល័យ

អ្នកអាចារ្យ ! យើងមានសេចក្ដីអាឡោះអាល័យសោកស្ដាយអ្នកអាចារ្យឥតមានភ្លេច ដែលធ្លាប់មានឧបការៈដល់គ្នាទៅវិញទៅមក កាលយើងទើបមកបួសនៅវត្តនេះ ឥតមានស្គាល់នរណាសោះ មានតែអ្នកអាចារ្យនេះហើយឧបដ្ឋាកបំរើយើងដោយកិច្ចវត្តមិនមានជិនធ្អន់ ក្នុងគ្រាដែលនៅជានវកភិក្ខុ យើងស្គាល់កិរិយាមារយាទអ្នកពីត្រឹមនោះមកថាជាមនុស្សប្រពៃងាយ មនុស្សដូចអ្នកនេះដូចគ្រាប់ឈើល្អ បើបណ្ដុះមុខជានឹងបានផល ៗ កាលគ្រូអនិច្ចធម្មទៅ មាតាបិតាអ្នកគាត់ខោអាវមកឲ្យអ្នកពីសាមណេរ ព្រោះគាត់ទៅរកទទួលទានថ្វាយ ក្រែងឈឺចាប់ពុំមាននរណាថែរក្សា យើងមានសង្ឃឹមថា វិជ្ជាព្រះបរិយត្តិ-ធម៌ដែលអ្នកបានសិក្សាហើយ នឹងបានផលទៅអនាគត គ្រូអនិច្ចធម្មទៅ រូបអ្នកដូចទំពាំងស្នងឫស្សី ទើបយើងទទួលភារៈពីមាតាបិតាអ្នកបកថែរក្សាដូចជាកូន អ្នកចង់ចេញទៅរៀនស្រុកក្រៅ ក៏ដឹកនាំឲ្យទៅរៀន លុះរៀនបានសំរេច ក៏ទទួលមកបង្ហាត់បង្ហាញជំនួសគ្រូដូចបំណង ៗ វត្តតោងពលពីដើមស្ដុកដោយព្រៃ វិហារកុដិសាលាក៏ទ្រុឌទ្រោមអស់ បានអ្នកជាកំឡាំងដៃស្ដាំ គ្រូស្រុតអ៊ុមជាកំឡាំងដៃឆ្វេង ព្រួតកំឡាំងគ្នា

ដោយសាមគ្គី ញើសហូរតាំងទឹកទាំងអស់គ្នា ក្រសួត្រអុឹមអនិច្ចធម្មទៅ យើងដូចជាកំបុតដៃម្ខាង ខ្ញុំអ្នកពីដើមការៈខាងបង្ហាត់បង្ហាញ លុះអត់អំពីក្រសួត្រអុឹមទៅ អ្នកប្រឹងជំនួសក្រសួត្រអុឹម ខ្ញុំអ្នកមួយដូចជាដៃស្តាំនឹងដៃឆ្វេងរបស់យើង អ្នកសឹកចេញពេលយើង អ្នកអង្វរសូមទទួលធុរៈថា "បើសឹកទៅក៏នៅតែធ្វើខ្ញុំព្រះ" តាមតែយើងហៅប្រើយប់ថ្ងៃគត់ទាស់ អ្នកប្តេជ្ញាថា រកទទួលគានបានទឹងទំនុកបំរុងគ្រូ រាប់អ្នកថាយ៉ាងណា កិរិយាប្រព្រឹត្តរបស់អ្នកក៏ទៅយ៉ាងនោះ អ្នកសឹកទៅ ៣ ឆ្នាំខំរកទ្រព្យបាន ដូចជាដញ្ញូនមកទុកជាសាសនសម្បត្តិទាំងអស់ ថែមទាំងដឹកនាំភរិយាអ្នកមកធ្វើជាឧបដ្ឋាយិកាបំរើសង្ឃក្នុងវត្តនេះទៀត យើងនឹកដល់សេចក្តីស្មោះសរសេចក្តីល្អរបស់អ្នក សូម្បីអ្នកអនិច្ចធម្ម ៤ ឆ្នាំហើយ ក៏នៅចាំតតក្លេប ៗ សមដូចពុទ្ធភាសិតថា រូបំ ជីរតិ មច្ចានំ នាមគោត្តំ ន ជីរតិ រូបរបស់សត្វទាំងឡាយ តែងទ្រុឌទ្រោមគ្រាំគ្រាទៅ, ឯនាមនឹងគោត្តមិនចេះគ្រាំគ្រាសាបសូន្យឡើយ ៗ

៥– ថ្ងៃ ៦ កើត ត្រង់នឹងថ្ងៃ ៤-៤-៤៩ វេលាព្រឹកប្រគេនយាគុ ថ្ងៃត្រង់ប្រគេនចង្ហាន់បិណ្ឌបាតដល់ព្រះសង្ឃ ២០០ រូប ។ ម៉ោង ១៨ ប្រជុំញាតិមិត្តសិស្សានុសិស្សនឹងមន្ត្រីគ្រប់ជំព្រមទាំងសម្តេចព្រះសង្ឃនាយកទាំងពីរគណៈនឹងមន្ត្រីសង្ឃឯទៀត និមន្តអញ្ជើញទៅជាអធិបតី ក្នុងព្រះពន្លាក់ក្តីនឹងបុរាំ ៗ មុននឹងបូជាសព ក្រុមសិស្ស

ចាស់នៃសាលាបង្រៀនប្រចាំខេត្តបាត់ដំបង សំដែងកំឡាប្លែកៗ នៅមុខបារាំយ៉ត ជូនលោកមន្ត្រីខ្មែរ - បារាំងមើលកំសាន្តចំនួន ១ ម៉ោង រួចហើយទើបព្រះតេជព្រះគុណព្រះមុនីកោសលមេគណខេត្តបាត់ដំបងថ្លែងសុន្ទរកថាជាភាសាខ្មែរដូចមានសេចក្តីតទៅនេះ ៗ

## សុន្ទរកថា

### ចំពោះមុខសព

សូមពិតពុទ្ធដីកាព្រះថេរានុត្ថេរៈទាំងឡាយ !

សូមជំរាបលោកអ្នកសប្បុរសទាំងអស់

អ្នកអាចារ្យហ៊ុន - សុជ ដែលពុទ្ធបរិស័ទនឹងបូជាវិលាយសពក្នុងខណៈនេះ ជាបុរសម្នាក់ប្រកបដោយសតិបញ្ញា ជាបណ្ឌិតឈ្លាសវាងវៃក្នុងផ្លូវលោកនិងផ្លូវធម៌ មានសុចរិយានិងបុគ្គលាៈទន់ភ្លន់ថ្លៃថ្នូរ គួរជាទីជ្រះថ្លាពេញចិត្តនៃពពួកពុទ្ធបរិស័ទ ជាប់បានជួយឧបត្ថម្ភដោយកំឡាំងកាយនិងកំឡាំងប្រាជ្ញាក្នុងកិច្ចកសាងទីសេនាសនៈ មានកុដិសាលានិងធម្មមន្ទីរជាដើម ហើយបានជួយទំនុកបំរុងការសិក្សាក្នុងព្រះពុទ្ធសាសនាទាំងខាងផ្នែកគន្ថធុរៈ និងវិបស្សនាធុរៈដល់ភិក្ខុសាមណេរនិងឧបាសកសិកាទាំងឡាយក្នុងវត្តពោធិវាលនេះ គាត់តែបានចំរើនរុងរឿងរៀងៗមកដល់សព្វថ្ងៃនេះ ៗ

ព្រះតេជព្រះគុណ !

លោកអ្នកសប្បុរសទាំងឡាយ !

កាលពីថ្ងៃម្សិលមិញនេះ ខ្ញុំព្រះករុណា - អាត្មាភាពបានថ្លែងប្រវត្តិអ្នកអាចារ្យ ហ៊ិន - សុជ ជាសង្ខេបរួចមកហើយ

ក្នុងឱកាសនេះ ខ្ញុំព្រះករុណា - អាត្មាភាពសូមថ្លែងគុណធម៌ប្រការខ្លះ នឹងសេចក្ដីអាឡោះអាល័យ ចំពោះសពអ្នកអាចារ្យ ហ៊ិន - សុជ យ៉ាងខ្លី ៗ ដើម្បីទុកជាទិដ្ឋានុគតិ និងជាទីសណ្ដាប់អស់លោកអ្នកសប្បុរសទាំងឡាយ ។

## កិត្តិគុណនិងគុណសម្បត្តិ

អ្នកអាចារ្យហ៊ិន-សុជនេះ កាលនៅពីកុមារកំពុងសិក្សាអក្សរសាស្ត្រក្នុងសំណាក់គ្រូបាអាចារ្យក្ដី មានវ័យវឌ្ឍនាការចំរើនឡើងហើយ បានបំពេញផ្នួសជាសាមណេរក្ដី ជាភិក្ខុក្ដី ដរាបដល់បានបង្ហាត់បង្ហាញសិស្សគណទាំងឡាយក្ដី ជាអ្នកមានសន្ដានចិត្តធូនធ្ងន់ ប្រកបដោយខន្តីសោរច្ចៈ និងសច្ចៈ ដែលជាគុណធម៌របស់មហាបុរស ជាអ្នកមានកាកប្បកិរិយាគួរឲ្យស្រឡាញ់ពេញចិត្តនៃ ។ បញ្ញាយាចារ្យ គួរឲ្យជាប់ចិត្តជ្រះថ្លា នឹងជាទីគោរពនៃសិស្សានុសិស្សរបស់ខ្លួន ព្រមទាំងសាសនិកជនទាំងឡាយ ។ ដោយសារគុណធម៌ដ៏ប្រពៃថ្លៃថ្លាទាំងនេះហើយ ដែលជាបច្ច័យយ៉ាងសំខាន់ បណ្ដាលឲ្យកិត្តិគុណរបស់អ្នកអាចារ្យ ផ្សាយក្លិនក្រអូបឈ្ងុយឈ្ងប់

សព្វថ្ងៃមខែត្របាត់ដំបងទាំងមូល ព្រមទាំងខែត្រជិតខាងខ្លះផង ។ ដោយកិត្តិគុណនិងគុណសម្បត្តិនេះហើយដែលជាកំឡាំងយ៉ាងធំរបស់ខ្ញុំព្រះករុណា - អាត្មាភាព ក្នុងកាលដែលអ្នកអាចារ្យមានជីវិតរស់នៅឡើយ ព្រោះអ្នកអាចារ្យ បានជួយកំឡាំងខ្ញុំព្រះករុណា - អាត្មាភាពខាងផ្លូវសម្ភារៈ ទាំងខាងផ្លូវគំនិត ជួយបំពេញកិច្ចខាងគន្ធធុរៈនិងវិបស្សនាធុរៈ ដរាបដល់កិច្ចការសាងផ្សេងៗ ឲ្យមានរបៀបរៀបរយល្អឡើង ទុកដូចជាដៃស្តាំរបស់ខ្ញុំព្រះករុណា អាត្មាភាពយ៉ាងពិតៗ ។

សេចក្តីថ្លែងអាល័យ

ព្រះតេជព្រះគុណ!

លោកអ្នកសប្បុរសទាំងឡាយ !

គួរឲ្យសោកស្តាយអ៊ីម្ល៉េះ! គួរឲ្យនឹកស្រណោះអ៊ីម្ល៉េះ! ចំពោះសពអ្នកអាចារ្យ ហ៊ិន - សុជ នេះ ដែលត្រូវមច្ចុរាជដ៏មានអំណាចឃោរឃៅមកផ្តាច់ផ្តិលអាយុសង្ខារ ក្នុងកំណត់អាយុ ៤៧ ឆ្នាំ ដែលជាវ័យកំពុងចំរើនដោយប្រការទាំងពួង ។

ឥឡូវនេះ យើងបានឃើញតែកេរ្តិ៍ដំណែលរបស់អ្នកអាចារ្យ មានកុដិសាលានិងធម្មមន្ទីរជាដើម ក៏ការរៀបចំទីភពមឲ្យមានរបៀបរៀបរយល្អមើលនេះគួរសរសើរដល់គំនិតនិងស្នាដៃរបស់អ្នកអាចារ្យណាស់ ! ។

នៃអ្នកអាចារ្យ ! ប្រសិនបើអ្នកនៅរស់រានមានជីវិតមកដល់ឥឡូវនេះសូមអ្នកមានបីតិភាពយ៉ាងក្រៃលែង នឹងស្ថានការណ៍បច្ចុប្បន្ន ហើយមុខជានឹងជំនួយធ្វើការយើងជាកំយោគពលឡើងទៀតពុំខាន ព្រោះអំពើដែលអ្នកបានសាបព្រោះមកហើយ ទើបតែនឹងចេញផ្លែផ្កាឃើញជាក់ស្តែង ក្នុងពេលនេះឯង ។

អ្នកអាចារ្យអើយ ! ថ្វីបើយើងនឹកសោកស្តាយអ្នក មិនចង់ឲ្យអ្នកព្រាត់ប្រាសចាកយើង ប៉ុន្តែដល់ពេលអ្នកត្រូវឈប់សំរាក ដោយអ្នកបានធ្វើការនឿយហត់ជាប្រយោជន៍ដល់ពុទ្ធសាសនាមកយូរហើយ បានស្មូគ្រត្រូវការឲ្យអ្នកឈប់សំរាក ឲ្យសមនឹងសេចក្តីនឿយហត់របស់អ្នកនៅលោកខាងនាយឯណោះ ។ ឯយើងទាំងអស់គ្នានៅខាងអាយឯណេះ ក៏មានចិត្តសោមនស្សណាស់ ចំពោះការឈប់សំរាកដ៏សុខក្សេមក្សាន្តជានិច្ចនោះ ហើយនៅឱកាសនេះ យើងបានមកជួបជុំធ្វើបុណ្យហែហមរំលាយសពអ្នកជាទឡ្ហិក ដើម្បីសំដែងឲ្យឃើញពស្តុតាងនៃសេចក្តីកតញ្ញូកតវេទី ចំពោះសពអ្នកនឹងគុណធម៌ដ៏ថ្លៃថ្លារបស់អ្នក ។ ហេតុដូច្នេះ យើងសូមឧទ្ទិស កុសលរាសីទាំងអម្បាលម៉ាននេះជូនអ្នកអាចារ្យ សូមអ្នកអាចារ្យអនុមោទនាទទួលយកចំណែកកុសលនេះចុះ ហើយសូមជាបច្ច័យឲ្យបានសំរេចនូវឥដ្ឋមនុញ្ញផល តាមបំណងរបស់អ្នកអាចារ្យកុំបីឃ្លាត ។

អ្នកអាចារ្យ ! យើងសូមលាអ្នកហើយ

អ្នកអាចារ្យ ! ក្រុមញាតិមិត្តអ្នកសូមលាអ្នកហើយ

អ្នកអាចារ្យ ! ក្រុមសិស្សានុសិស្សព្រមទាំងភរិយា

អ្នក សូមគោរពលាអ្នក លែងបានជួបមុខទៀតហើយ !

ក្នុងទីបំផុតនេះ ខ្ញុំព្រះករុណា អាត្មាភាពសូមថ្លែងអំណរអរគុណដោយគោរពចំពោះព្រះថេរានុត្ថេរៈទាំងអស់ មានសម្តេចព្រះសង្ឃនាយកទាំងពីរគណៈជាដើម នឹងអស់លោកអ្នកសប្បុរសទាំងឡាយ ដែលបាននិមន្ត - អញ្ជើញមកជួបជុំក្នុងពិធីបុណ្យឈាបនកិច្ចសពអ្នកអាចារ្យ ហ៊ិន-សុជនេះ ហើយសូមអានុភាពនៃកុសលបុញ្ញរាសីនេះ ផ្តល់នូវគជមនុញ្ញ-ផលតាមបំណងគ្រប់ៗ រត្តិទិពក្នុំបីឃ្លាតឡើយ ។

លំដាប់អំពីសុន្ទរកថានេះទៅ លោកភិន - ឆាំនថ្លែងប្រែជាភាសាបារាំង លុះចប់លោក•កញ្ញាជំទិតព្រះស្តេច ( ប៉ាក់-ប៉ុន ) នាំទៀនទៅសូមភ្លើងអំពីសម្តេចព្រះសង្ឃនាយកទាំងពីរគណៈ ទៅដុតលស់លើបារាំយ៉ត ហើយអស់លោកមន្ត្រីខ្មែរ - បារាំងយកធូបនឹងទៀនជួបទៅបូជាសព ។ ព្រះសង្ឃ ៤ រូបគង់ចាំទិសទាំង ៤ ហើយចំរើនអសុភកម្មដ្ឋានព្រះបាឡាត់ ធម្មនី ( លី ) វត្តបទុមវតីសំដែងធម៌ទេសនាមុខសព ។ តពីនោះ អស់លោកមន្ត្រីខ្មែរ – បារាំងក៏អញ្ជើញត្រឡប់ទៅគេហដ្ឋាន

រៀងៗខ្លួនវិញ ទើបក្រុមញាតិមិត្តនឹងសិស្សានុសិស្ស ព្រមទាំងភរិយា ចូលរើសអដ្ឋិធាតុ ហើយលាងដាក់ក្នុងពានប្រាក់យកទៅដំកល់លើតុនៅទីធម្មសភា ទើបនិមន្តព្រះសង្ឃចំរើនព្រះបរិត្តលុះចប់និមន្តព្រះតេជព្រះ-គុណ ព្រះពុទ្ធវង្ស នឹង ព្រះតេជព្រះគុណ ព្រះពោធិវង្ស សំដែងធម៌ទេសនាសង្គាយនា ។

៦ — ថ្ងៃ ៧ កើត ត្រង់នឹងថ្ងៃ ៥-៤-៤៩ វេលាព្រឹកប្រគេនយាគូ ថ្ងៃត្រង់ប្រគេនចង្ហាន់បិណ្ឌបាតដល់ព្រះសង្ឃ ២០០ រូប ហើយដាររវេរធ្វើបុណ្យជាការស្រេច ។

---

# អំពីតាំងចៅអធិការ

(តមក)

សញ្ញាប័ត្រលេខ ២៥០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូធីង-មៅ នាមឆាយា ធម្មត្ថេរ កើតឆ្នាំកុរ អាយុ ៣៨ វស្សា ១៧ ជាចៅអធិការ វត្តត្រពាំងគង់ ឃុំត្រពាំងគង់ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ២៥១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូសូរ-ម៉ៃ នាមឆាយា ធម្មជោត កើតឆ្នាំមមែ អាយុ ៣០ វស្សា ១០ ជាគ្រូសូត្រស្ដាំវត្តត្រពាំងគង់ ឃុំត្រពាំងគង់ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ២៥២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូរង់-ភ៉ត· នាមឆាយា បញ្ញាជោត កើតឆ្នាំវក អាយុ ២៩ វស្សា ៩ ជាគ្រូសូត្រឆ្វេងនៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៥៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូគាំ-នៅ នាមឆាយា មុនិយត្ថេរ កើតឆ្នាំថោះ អាយុ ៤៦ វស្សា ២៥ ជាចៅអធិការវត្តបទុមសាគរ ឃុំផ្ទះកណ្ដាល ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ៨ ចុះថ្ងៃ ៩-៩-៤៨ តាំងលោកគ្រូ ចាន់-ស៊ី នាមធាយា ខេមរោ អាយុ ៥៣ វស្សា ៣៣ ជាចៅអធិការវត្តកោះសុខ ឃុំទ្រា ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។

សញ្ញាប័ត្រលេខ ៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុក-អ៊ុម នាមធាយា អគ្គសិរិ អាយុ ៦០ វស្សា ៣១ ជាចៅអធិការវត្តធម្មវិទយារាម ឃុំស្មោ ស្រុកព្រៃកប្បាស ខេត្តតាកែវ ។

សញ្ញាប័ត្រលេខ ២៥៤ ចុះថ្ងៃព្រហស្បតិ៍ ប្រាំមួយកើតខែភទ្របទ ឆ្នាំជូតសំរឹទ្ធិស័ក តាំងលោកគ្រូ ង៉ៅ-កត នាមធាយា តន្ទុជោត កើតឆ្នាំច អាយុ ៣៩ វស្សា ១៦ ជាចៅអធិការវត្តព្រះពុទ្ធឯកភាព ឃុំកំពង់ឃ្លាំង ស្រុកជីក្រែង ខេត្តសៀមរាប ។

សញ្ញាប័ត្រលេខ ២៥៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ព្រាប-ស៊ុប នាមធាយា តន្ទុត្ថេរ កើតឆ្នាំជូត អាយុ ៤៩ វស្សា ២៩ ជាគ្រូសូត្រស្តាំវត្តកំពង់ឃ្លាំង ឃុំកំពង់ឃ្លាំង ស្រុកជីក្រែង ខេត្តសៀមរាប ។

សញ្ញាប័ត្រលេខ ២៥៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ កុយ-ធួន នាមធាយា ចន្ទសុវណ្ណោ កើតឆ្នាំរក អាយុ ២៩ វស្សា ៩ ជាគ្រូសូត្រឆ្វេងនៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៥៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គូ-ជា នាមធាយា ព្រហ្មសារ កើតឆ្នាំច អាយុ ៥១ វស្សា ៣០ ជា

គ្រូសូត្រស្តាំវត្តល្វា ឃុំ កំពង់ឃ្លាំង ស្រុកជីក្រែង ខេត្តសៀមរាប ។ល។

សញ្ញាប័ត្រលេខ ២៥៨ ចុះថ្ងៃព្រហស្បតិ៍ ៦ កើតខែភទ្របទ ឆ្នាំជូតសំរឹទ្ធិស័ក តាំងលោកគ្រូ ហែម-ស៊ូ នាមធាយា សទ្ធម្មប្បញ្ញោ កើតឆ្នាំច អាយុ ៣៩ វស្សា ១៨ ជាចៅអធិការវត្តព្រៃស្នៀត ឃុំព្រៃស្នៀត ស្រុកពារាំងខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ២៥៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ញ៉ែម-ណាំ នាមធាយា ជោតិប្បញ្ញោ កើតឆ្នាំកុរ អាយុ ៥០ វស្សា ១៥ ជាគ្រូសូត្រស្តាំ នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៦០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ប-ទូច នាមធាយា មុនីបញ្ញាជោត កើតឆ្នាំជូត អាយុ ៣៧ វស្សា ១៥ ជាគ្រូសូត្រឆ្វេងនៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៦១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ បាន់-ណាក នាមធាយា ធម្មសរ កើតឆ្នាំរកា អាយុ ២៨ វស្សា ៨ ជាគ្រូសូត្រស្តាំ វត្តមេលោង ឃុំព្រៃស្នៀត ស្រុកពារាំង ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ២៦២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មាស-អៃ នាមធាយា សទ្ធម្មប្បញ្ញោ កើតឆ្នាំមមែ អាយុ ៣០ វស្សា ៧ ជាគ្រូសូត្រឆ្វេងនៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។ (មានត)

# សូមជូនដំណឹង

ការផ្សាយរបស់ក្រុមពុទ្ធសាសនបណ្ឌិត្យ ដែលអាក់ខានបោះពុម្ពមកយូរហើយ ដោយខ្វះអក្សរ នឹងក្រដាស ឥឡូវនេះ ចាប់ផ្ដើមបោះពុម្ពបានឡើងវិញហើយ មានសៀវភៅកាណាក់ៈ បាលី, សម្ពន្ធមាលា, បាដិមោក្ខសង្ខេប, ពិធីទានសមាសសង្ខេបជាភាសាបារាំងនឹងរឿងមួយពាន់មួយយប់ជាដើម ដែលទើបនឹងចេញពីរោងពុម្ពក្នុងពេលថ្មីៗនេះ ហេតុនេះ បើអស់លោកអ្នកប្រាថ្នាចង់បានសៀវភៅដូចមានឈ្មោះខាងលើសូមអញ្ជើញចូលទៅជាវនៅក្រុមពុទ្ធសាសនបណ្ឌិត្យតាមត្រូវការ ។

ក្រុមពុទ្ធសាសនបណ្ឌិត្យ

IMPRIMERIE ROYALE